ខ្មែរប៉ុស្តិ៍
ឆ្នេរខាងកើត
THE KHMER POST
EAST COAST
The Cambodian-American Biweekly News


Email : Khmerpostusa@gmail.com
Call : 267-254-8758


Welcome to ២០១០


VOLUME 04 ISSUE 51 January 15th - 28th 2010


# ស្វាគមន៍ឆ្នាំ ២០១០ ក្នុងសន្តិភាព

**ដោយ : ពិន សំខុន**

•••ឆ្នាំថ្មីបានមកដល់ពេញមួយថ្ងៃហើយ នារាត្រីទី១ នៃឆ្នាំ២០១០ នោះ ខ្មែរប៉ុស្តិ៍ បានប្រារព្ធពិធីជប់លៀងជាមួយបងប្អូនខ្មែរ ក្នុងសហគមន៍ ប្រមាណ ១៥០នាក់ នៅភោជនីយដ្ឋាន "កាវី" ដែលទើបនិងផ្តើមបើកទ្វារទទួលភ្ញៀវប្រមាណជា២ខែមកហើយ ។ បានបើកទំព័រថ្មីជូនពលរដ្ឋខ្មែរ នៅហ្វីឡាដែលហ្វៀ ថា "ពិភពលោកនេះ និងស្ថិតនៅក្នុងកណ្តាប់ដៃនៃនរណាម្នាក់ដែលហ៊ានក្រោកពីព្រលឹម" ។ នៅថ្ងៃដើមឆ្នាំដែលនឹងបន្តទៅយ៉ាងវែងអន្លាយមិនអាចទប់បាន បងប្អូនខ្មែរបានណែនាំគ្នាឱ្យមកជួបជុំជាមិត្តភាពគ្មានបក្ខពួក គ្មានកាន់វណ្ណៈ គ្មានកាន់ការប្រកែកប្រកាន់


ឆាករឿងទុំទាវ ដោយ សុភក្ត្រ និង វ៉ានី ដឹកនាំដោយលោក គីម ភឿន

យើងឧទ្ទិសរាត្រីនោះថា ជារាត្រីរបស់សហគមន៍ ជារាត្រីសមោសរនៃសន្តិភាព និងជារាត្រីនៃការអបអរសាទរដល់ក្រុមគ្រួសារខ្លួនឯង ។

ថ្ងៃទី១ ខែមករា ឆ្នាំ២០១០ ធ្លាប់ជាថ្ងៃដ៏ស្ងប់ស្ងាត់ក្នុងទម្លាប់ច្រើនឆ្នាំមកហើយ តែឆ្នាំនេះ ខ្មែរប៉ុស្តិ៍ ហើយលើនេះ ជាពិសេស គ្មានបំណងប្រមូលលុយទៅជួយនរណាក្រៅ ហើយក៏គ្មានប្រាថ្នាអ្វីក្រៅពីការមកកម្សាន្តជាគ្រួសារតែប៉ុណ្ណោះ ។

ខ្មែរប៉ុស្តិ៍ មានបំណងបំពេញតួនាទីមួយថ្មីទៀត

តទៅទំព័រទី ០៩

# គឹម សុខា នៅសហរដ្ឋអាមេរិក

•••គណបក្សសិទ្ធិមនុស្ស បានរៀបចំបដិសណ្ឋារកិច្ចជូនប្រធានគណបក្សរបស់ខ្លួន គឺលោក កឹម សុខា ដែលទើបនឹងមកពីភ្នំពេញ ដល់ក្រុងហ្វីដែលហ្វៀ រដ្ឋផែន-ស៊ីវេនា កាលពីថ្ងៃសៅរ៍ ទី៩ មករានេះ ។ លោក កឹម សុខា បានទទួលពរជ័យន្តោពីព្រះសង្ឃ រួចហើយធ្វើដំណើរតួរសមចំពោះភ្ញៀវប្រមាណ ១៥០នាក់ ដែលបានអញ្ជើញមកចូលរួមនៅភោជនីយ-ដ្ឋានខ្មែរ "កាវី" ដែលស្ថិតនៅខាងត្បូងហ្វីឡាដែលហ្វៀ ។



លោក កឹម សុខា ថ្លែងសុន្ទរកថា ទៅកាន់ភ្ញៀវ នៅហ្វីឡាដែលហ្វៀ

លោក ពេជ្រ វិសាកា ប្រធានសាខាប្រចាំរដ្ឋផែនស៊ីវេនា បានឡើងថ្លែងស្វាគមន៍ក្នុងនាមនៃសមាជិកទាំងអស់ មកពីតំបន់ឆ្ងាយជិតជូនដល់ប្រធាន ។ -បន្ទាប់មកលោក ម៉ម យីន ជាទីប្រឹក្សាបានឡើងថ្លែងពីសមក្មភាពគណបក្សក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ ។ ពិធីករ ប៊ុនរ៉ាត ម៉ាត ក៏បានអញ្ជើញលោក កឹម សុខា មកថ្លែងសុន្ទរកថារាយការណ៍ពីនយោបាយកម្ពុជា **តទៅទំព័រទី ១០**

# ៧ មករា នៅហ្វីឡាដែលហ្វៀ

•••មិនមែននៅតែភ្នំពេញទេ ដែលគណបក្សបជាជនប្រារព្ធពិធីជប់លៀង នាឱកាសបុណ្យ ៧ មករា ដែលរំលឹកពីការបណ្តេញប៉ុល ពត ចេញពីអំណាចដោយវៀតណាម នៅហ្វីឡាដែលហ្វៀ សហ-រដ្ឋអាមេរិក ក៏បានធ្វើពិធីនេះដែរ កាលពីថ្ងៃ ៩ មករា ២០១០មុននេះ នៅភោជនីយដ្ឋាន "ញូគោលដិន ប៉ាលេស" ។ ពិធីនេះចូលរួមដោយលោកឯកអគ្គរាជទូត សៀ កុសល ប្រចាំ អ.ស.ប និងលោកឯកអគ្គរាជទូត ហែម ហេង នៃព្រះរាជាណាចក្រកម្ពុជាប្រចាំរដ្ឋធានីវ៉ាស៊ីនតុនផងដែរ ។


គណកម្មាការនាយកសាខាគណបក្សប្រជាជន នៅហ្វីឡាដែលហ្វៀ នាឱកាសទិវា ៧ មករា

មានភ្ញៀវដ៏គួរឱ្យកត់សំគាល់ក៏បានចូលរួមដែរ គឺ លោក ហ៊ុន ម៉ានី ជាកូនរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សោម សាត្ថនា ហៅម៉ាយ៉ារិទ្ធ អតីតបុគ្គលិកអាស៊ីសេរី ***តទៅទំព័រទី ០៧***




# FOR SALE BY OWNER

HASS'S AUTO COLLISION & BODY SHOP
615 W. Fisher Avenue. Philadelphia, Pa 191203




HASS'S AUTO ជួសជុលតួឡានដែលបុគ្គលម្ចាស់ហាងចូលនិវត្តន៍
-ហាងមានដំណើរការ១៧ឆ្នាំមកហើយ-ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវ
លោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន
-ទិញដីជាមួយនឹងផ្ទះក៏បាន-ទិញទាំងពីររួមគ្នាក៏បាន
បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

**267-242-7938**

Owner is retiring. 17 years in business at this location.
Well established business, all seasons are busy.
Option to buy only business, real estate, or both.

**For more information, please contact Nick at 267-242-7938**


# WELCOME 2010

## Happy New Year from the Khmer Post Newspaper

Dannaly Sam
January 1, 2010

Philadelphia, PA-The start of the year 2010 began with a festive celebration by the Khmer Post Newspaper on the night of January 1st to celebrate the New Year and the past years' hard work. The celebration was held at the Kavei Restaurant where friends and guests enjoyed a night filled with skits, acts, song and dance, and delicious Khmer cuisine. One of the highlights of the night was the honoring of the Cambodian soldiers with a ceremony that recognized some of the soldiers' commitment to the Army. The ceremony consisted of a speech and ceremonial badge wearing. One of the acts featured was an act given by Mam Yin where he read a poem that pleaded with Philadelphia's youth to stay in school and steer out of trouble's ways. This act featured actors who portrayed the archetypes of lazy persons who have dropped out of school in an effort to try to convince adolescents to stay in school. There was also a skit that featured a few actors and actresses who played the traditional Cambodian folk-tale of "Tum Teav" with a comical twist where the lead-male called "Tum" resurrects to sing his song to his parted love "Teav" only to die once more. In addition to the fun, there were also raffles where guests had the chance to win memorable souvenirs such as pots, mugs, and a stereo system.



Master Cemeny-Sabane tach-Pin Somkhon- Roeum Long


# Yoo's Auto Service and Collision

យូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

ផ្នែកខាងម៉ាស៊ីន

- Check Engine Light Diagnostic
- Electronic Wheel Alignment
- Certified Enhanced Emission
- Inspection & Repairs
- Muffler & More

FREE ESTIMATES

យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

**COUPON**
$10 OFF TOWARD EMISSION AND STATE INSPECTION

ផ្នែកជួសជុលតួរថយន្ត

- Expert Body Work
- Fender & Paint Work
- Frame Straightening
- Insurance Specialists



ទូរស័ព្ទរក SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475
189 W. Duncannon Ave. Phila., PA 19120

# សន្និសីទពិភាក្សាស្ដីពីទិវា៧មករានៅសាទីយ៉ុង

**ដោយ : គីមភៀន**

•••សន្និសីទពិភាក្សារបស់សហគមន៍ខ្មែរ នៅប្រទេសបារាំង កាលពីថ្ងៃទី៣ មករា ២០១០ នេះ បានវាយតម្លៃខួបថ្ងៃទី ៧ មករា ១៩៧៩ នៅកម្ពុជា ថា "ជាថ្ងៃមហាជោគជ័យនៃអាណានិគមយួន នៅកម្ពុជា"

គណកម្មាធិការពិសេស ដែលមានតំណាងមកពីគណកម្មាធិការព្រំដែនកម្ពុជា, គណបក្សសិទ្ធិមនុស្ស គណបក្ស សម រង្ស៊ី, សម្ព័ន្ធខ្មែរការពារសិទ្ធិមនុស្ស និងបូរីជន... បានបើកកិច្ចពិភាក្សា ហើយសំដែងជាសាធារណពីការមិនពេញចិត្តចំពោះរបបភ្នំពេញ ដែលកើតចេញមកពីព្រឹត្តិការណ៍ថ្ងៃទី ៧ មករា ១៩៧៩ ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពីទីក្រុងភ្នំពេញ បានសំដែងការក្រេវក្រោធចំពោះសកម្មភាពប្រឆាំង និងការផ្សាព្វផ្សាយប្រឆាំងនឹងរបប ៧ មករា ដែលបង្ហាញខ្លួនកាន់តែខ្លាំងក្លាឡើងជាលំដាប់ ក្នុងស្រុកក៏ដូចនៅក្រៅប្រទេស ។

លោក ឌី ការ៉េត អតីតអ្នកធ្វើអត្ថាធិប្បាយលើទំព័រកាសែតខ្មែរឯករាជ្យ និងនគរធំ បានផ្ដល់ការវិភាគ និងរំលឹកប្រវត្តិសាស្ត្រ នាឱកាស សន្និសីទនោះដូចតទៅ :

**វិធីបញ្ចូលអាណានិគម យួននៅកម្ពុជា**



(សេចក្ដីថ្លែងការណ៍របស់លោក ឌី ការ៉េត ក្នុងសន្និសីទពិភាក្សា នាថ្ងៃទី៣ មករា ២០១០ នៅទីក្រុងសាទីយ៉ុងប្រទេសបារាំង)

នៅថ្ងៃទី៧ មករា ១៩៧៩នោះវាមិនមែនជាលើកទី១ទេ ដែលពួកយៀក (ហៅថា យួន ឬ អាណ្ណាមិក ឬវៀតណាម) បានចូលមកយកកម្ពុជា ធ្វើជាអាណានិគម និងលេបបញ្ចូលទៅក្នុងចក្រភពរបស់គេ ។ លើកទី១ គឺនៅក្នុងសតវត្សទី១៧ ក្នុងរាជ្យស្ដេចខ្មែរព្រះបាទជ័យ-ជេដ្ឋាទី២ ដោយយួនបានទទួល "ដីសម្បទាន" នៅកោះក្របីដែលនឹងរីកក្លាយជាក្រុងព្រៃនគរ-សៃហ្គង។ អ្នកប្រវត្តិវិទូ ខ្លះបានបន្សល់ឯកសារយ៉ាងលំអិតអំពីវិធីរបស់ពួកស្ដេចចក្រពត្រយួន ធ្វើការលុកលុយចូលកាន់កាប់ការធ្វើអាណានិគម និងធ្វើ "យួនូបនីយកម្ម" នៃកម្ពុជា ដែលមិនខុសប្លែកអំពីវិធីដែលគេបានធ្វើ ដើម្បីកំទេចជនជាតិចាម ហើយស៊ីលេបរាជាណាចក្រចាមទេ ។ នៅចុងសតវត្សទី២០វិញ នយោបាយវាតទីនិយមរបស់វៀតណាម "សង្គមនិយម" ក៏ជាការបន្តនយោបាយរបស់ពួកស្ដេចចក្រពត្រយួន នៃសតវត្សមុនៗប៉ុណ្ណោះ។

**នៅសតវត្សទី១៩ ខ្មែរត្រូវក្លាយខ្លួនជាយួន**

អ្នកប្រវត្តិវិទូបារាំង អាដេម៉ារ ឡឺក្លែរ (Adhémard LECLERE) បានកត់ទុកថា ស្ដេចចក្រពត្រយួន ឈ្មោះ មិញ-ម៉ាង ដែលរៀបចំ "ការលេបយកកម្ពុជា" បានផ្ដើមសេចក្ដីឱ្យព្រះនាង អង្គម៉ី ធ្វើជាមហាក្សត្រិយានីខ្មែរ ដើម្បីជាឡប់ឡែ បាំងអំណាចដ៏ខ្លាំងក្លានៃមហាឧត្ដមសេនីយយួន អុង ទៀង-តួន ដែលជាបេបញ្ជាការនៃរដ្ឋមន្ត្រីទាំងអស់ ។ ការដឹកនាំរដ្ឋាភិបាលនៃអាណាចក្រខ្មែរ ត្រូវបានប្រគល់ជូនឧត្ដមសេនីយយួនបីនាក់ទៀត គឺ ទ្រឿង មិញ យ៉ាង, ផាំ យ៉ាំង ដឿន និង ត្រាន់ យ៉ាំង ណាង ដោយមានជំនួយការនៃរដ្ឋមន្ត្រី និងចៅហ្វាយខេត្តខ្មែរ ។ ឈ្មោះទីក្រុង និងខេត្តខ្មែរទាំងអស់ ត្រូវគេដាក់ឈ្មោះយួនមកជំនួស ។ គេហៅទីក្រុងភ្នំពេញ ថា *ណាមយ៉ាង* (ឬ *ណាមប៉ីយ៉ាង*) ខេត្តព្រៃវែង ថា *ឡាវែន*, ខេត្តក្រចេះ ថា *កន់សេ* ។ល។ នៅពេលនោះសោត នាម៉ឺនមុខមន្ត្រីខ្មែរ ត្រូវបោះបង់សំពត់អាវខ្មែរ ហើយស្លៀកពាក់ខោអាវយួនវិញ បួងសក់ក្បាលដូចយួន និងនិយាយទៅកាន់ចៅហ្វាយខ្លួនដោយភាសាយួន។ នៅគ្រប់ខេត្តទាំងអស់វិញ វាមាន "អ្នកប្រចាំការយួន នៅជាប់នឹងចៅហ្វាយខេត្តខ្មែរជានិច្ច ដើម្បីពិនិត្យតាមដានលើកិច្ចការ និងការចាត់ចែងរដ្ឋបាលរបស់ចៅហ្វាយខេត្តនេះ" ។ ម្យ៉ាងទៀត ដូចគេបានធ្វើនៅប្រទេសចាមរួចហើយដែរ ពួកអាណានិគមយួនបានបន្ថយ ឬក៏ហាមប្រាមតែម្ដង មិនឱ្យមានការបង្រៀនភាសា និងអក្សរខ្មែរទេ។ ពិធីព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវគេបង្ខំឱ្យកែប្រែតាមពិធីសាសនាយួនវិញ ។ ព្រះសង្ឃខ្មែរ ដែលរឹងរូសនឹងគោលការណ៍របស់គេ ត្រូវគេរករឿងចាប់ផ្សឹកទាំងអស់ ។ ចេតិយដែលរក្សាធាតុម្ដាយ-ឪពុក- ជីដូន-ជីតាខ្មែរ ក៏ត្រូវគេគាស់រំលំចោល ហើយដើមពោធិធំៗ នៅក្នុងទីវត្តក៏ត្រូវគេកាប់ជំរះបំបាត់ស្នាមដែរ ។

នៅឆ្នាំ១៩៧៩ ដែលពួកយៀកបានលុកលុយចូលកាន់កាប់ស្រុកខ្មែរជាថ្មី ពួកមេបញ្ជាការកុម្មុយនីស្តនៃក្រុងហាណូយ បានអនុវត្តន៍ក្នុងភាគធំនូវរូបមន្តរបស់ដូនតាគេនោះ ដើម្បីត្រួតត្រាស្រុកខ្មែរដែរ ។

ប៉ុន្តែគេបានកែលំអចំណុចសំខាន់មួយ : ស្ដេចយួន មិញ-ម៉ាង ក៏ដូចគ្នានឹងស្ដេចយួនសម័យមុនៗដែរ បានប្រាថ្នាធ្វើឱ្យខ្មែរ ក្លាយជាយួន រីឯពួកយួននៅសម័យនោះ បានប្ដេជាធ្វើខ្លួនជាខ្មែរតែម្ដង ដើម្បីបំភាន់មតិលោកបានស្រួល និងដើម្បីធ្វើឱ្យ "ស្ថានភាព

**តទៅទំព័រ០៤**

The Khmer Post Directory
East Coast Publication
Regional Editor : Pin Samkhon
Email : pinsamkhon@gmail.com
Writers : Mam Yin, Kim Phean, Dannaly Sam
Advertising
Marketing Manager : Sabane Thach
Phone : 267-253-3947
Email : sabane.thach@gmail.com

V P Auto Center
បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច
■Mechanic Service ■Body Repair ■State Inspection ■Towing Service
យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

រោងជាងម៉ាស៊ីន
តម្រង់កង់ដោយកុំព្យូទ័រ
ការងារអេឡិចត្រូនិច
ធ្វើម៉ាស៊ីនត្រជាក់-ម៉ាស៊ីនក្ដៅ
ត្រួតពិនិត្យខាងបញ្ចេញផ្សែង
ធ្វើម៉ូរស័រ
ធ្វើបំពង់ផ្សែង
បូមប្រេង
....នឹងធ្វើច្រើនទៀត



រោងជួសជុលតួរថយន្ត
គុណភាពខាងលាបថ្នាំ
ប្ដូរគ្រឿងបន្លាស់ត្រឹមត្រូវ
ជួសជុលសម្បកឡាន
យើងអាចហៅទៅនិយាយជាមួយ អិនស្វិរិនជួសលោកអ្នកបាន
យើងវាយតម្លៃការងារឥតគិតថ្លៃ ។



រោងជាងម៉ាស៊ីន
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
State Inspection 50$
Muffler & More

រោងជួសជុលតួរថយន្ត
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists

601W. Fisher Ave. Phila., PA 19120
Tel : 215-455-9999/215-329-4444/ Fax : 215-455-3757



# ប្រវត្តិសាស្ត្រថ្មីលើដីហ្វីឡា

**ដោយ : អ៊ុម លឿម**

•••ថ្ងៃទី១ ខែមករា ឆ្នាំ២០១០ អាចរាប់បានថា ជាថ្ងៃប្រវត្តិសាស្ត្រមួយ សម្រាប់សហគមន៍ខ្មែរ នៃទីក្រុង ហ្វីឡាដែលហ្វៀ ដែលជាសហគមន៍ល្បីល្បាញខាងសម្បូរ ទៅដោយភាពចម្រុះនៃគណបក្សនយោបាយផ្សេងៗ សហគមន៍នានា និងក្រុមផ្សេងៗដោយក្នុងនោះក៏រាប់ បញ្ចូលទាំងវិសាលភាពនៃការគោរពលើជំនឿសាសនា មានទាំងវិហារគ្រីស្ទសាសនារាប់សិបកន្លែង និងវត្តអារាម របស់អ្នកគោរពលើពុទ្ធសាសនាជាច្រើន ។ល។ ដែល សកម្មភាពទាំងនោះ សមទៅនឹងអ្វីដែលហៅថា " ប្រជាធិបតេយ្យ"ដ៏ពិតប្រាកដនោះឯង ។

ចំពោះពាក្យថា "ប្រវត្តិសាស្ត្រថ្មី" ដែល "ខ្មែរប៉ុស្តិ៍" លើកយកមកនិយាយនៅពេលនេះ គឺសំដៅទៅលើក្តី ស្រឡាញ់រាប់អានរវាងក្រុមបក្ស អង្គការ ឬសមាគមនានា ជាដើម ដែលបានបង្ហាញនូវភាពស្រឡាញ់ សាមគ្គីរវាងគ្នា និងគ្នាក្នុងឱកាសរាត្រីសមោសរមួយ ដែលសារព័ត៌មាន "ខ្មែរប៉ុស្តិ៍" បានប្រារព្ធធ្វើឡើង សម្រាប់អបអរឆ្នាំថ្មីនារាត្រី ថ្ងៃទី១ មករា កន្លងមកនេះ នៅឯភោជនីយដ្ឋានខ្មែរ ជា លើកដំបូងគេបំផុតមួយ នៅលើទឹកដីហ្វីឡាដែលហ្វៀ ផ្នែក ខាងត្បូង ស្ថិតនៅបណ្តោយផងវិថីអូវីហ្គេន ។

គួរកត់សំគាល់ថា ចាប់តាំងពីដើមដំបូងមក ថ្វីបើ សហគមន៍ខ្មែរមួយនេះ និយាយភាសាអាចស្តាប់គ្នា បាន យ៉ាងងាយស្រួលក៏ពិតមែន តែការប្រកាន់រើសអើងនូវ បក្សក្រុមផ្សេងៗ បានធ្វើឱ្យក្រុមខ្មែរទាំងនោះមានការវាយ ប្រហារខាងពាក្យសំដីដាក់គ្នាជាហូរហែរ ដែលទង្វើរទាំង នោះ ជាកត្តារាំងស្ទះសម្រាប់ការអភិវឌ្ឍន៍ក្នុងសហគមន៍ ។

តែផ្ទុយទៅវិញ សម្រាប់ឆ្នាំថ្មីនេះ ក្តីសង្ឃឹមថ្មី ក៏បាន ចាប់បដិសន្ធិឡើង សម្រាប់សហគមន៍ដែលធ្លាប់មាន សភាពអាប់អួរ ត្រូវបានប្រែក្លាយជាសហគមន៍ដែលពោរ ពេញទៅដោយការរួបរួមគ្នា សាមគ្គី ទោះបីក្រុមនីមួយៗ នៅតែកាន់នូវនិន្នាការរបស់ក្រុមរៀងៗខ្លួនយ៉ាងណាក៏ ដោយចុះ ហើយសកម្មភាពទាំងនេះ គឺជាសារមួយបង្ហាញ នូវភាពរីកចម្រើនក្នុងសហគមន៍លើសពីពេលមុន ។

តាមរយៈកម្មវិធីរាត្រីសមោសរ សម្រាប់អបអរឆ្នាំថ្មី ដែលរៀបចំឡើងដោយកាសែត "ខ្មែរប៉ុស្តិ៍" នាពេលថ្មីៗ កន្លងមកនេះ គេសង្កេតឃើញវត្តមានរបស់ក្រុមផ្សេងៗ ជាច្រើន ដូចជាក្រុមអតីតយុទ្ធជន ដែលបានគ្រងឯកសណ្ឋាន ទ័ពយ៉ាងប្រណិត , សហព័ន្ធខ្មែរកម្ពុជាក្រោម, សមាគម ខ្មែរ, សហគមន៍មរណៈសង្គ្រោះ, សាខាគណបក្សសិទ្ធិមនុស្ស ប្រចាំរដ្ឋផែនស៊ីវែនញ៉ា, សាខាគណបក្ស សម រង្ស៊ី ប្រចាំ ទីក្រុងហ្វីឡាដែលហ្វៀ, តំណាងពាណិជ្ជករខ្មែរ, ព្រមទាំង អង្គការនានា ដោយក្នុងនោះក៏រួមមានទាំង តំណាងគណៈ-កម្មាការវត្ត និងតំណាងគ្រូគង្វាលគ្រីស្ទសាសនា ក៏ត្រូវបាន ចូលរួមផងដែរ ដោយក្រុមនីមួយៗ បានបង្ហាញនូវការ ស្វាគមន៍យ៉ាងរាក់ទាក់ចំពោះគ្នានឹងគ្នា ប្រកបដោយទឹក មុខរួសរាយ ។

ជាមួយគ្នានេះ "ខ្មែរប៉ុស្តិ៍" សូមចូលរួមស្វាគមន៍ ជាមួយនឹងសកម្មភាពនៃក្តីស្រឡាញ់ ដែលបានផុសឡើង ក្នុងសហគមន៍ខ្មែរដ៏តូចចង្អៀតនេះ ហើយក៏សូមឧទ្ទិស ឱ្យក្តីស្រឡាញ់ សាមគ្គីនេះស្ថិតនៅជានិច្ចនិរន្តន៍ ៕


# ក្រុមហ៊ុនទេសចរណ៍ខ្មែរ

Since 1997

ក្នុង និងក្រៅប្រទេស

LOW FARE TRAVEL, NIC.

Domestic & International

OFFICE IN THE UNITED STATES

CALIFORNIA-FLORIA-ILLINIOS-N.COLOLINA-MASSACHUSET

មានសេវាបំរើ
-លក់សំបុត្រក្នុង/ក្រៅស្រុក
-ថតរូប Passport
-ធ្វើ Passport
-បកប្រែឯកសារ
-Lowyer referrals

**1800 s. 15TH Street. . Philadelphia , PA 19145 USA**

តម្លៃថោកពិសេសទៅស្រុកខ្មែរ,ឡាវ និង វៀតណាម

Special offers to Cambodia/Lao, Thai & Vietnam :

ទៅលេងស្រុកខ្មែរ......

មានតម្លៃពិសេសជូនលោក លោកស្រី លោកយាយ លោកតា បងប្អូន មីងមា ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ បុណ្យអុំទូក អកអំបុក និងសំពះព្រះខែ ។

សូមជ្រើសរើសយន្តហោះដែលលោក លោកស្រី លោកយាយ លោកតា បងប្អូន មីងមា ចង់ជិះធ្វើដំណើរតាមបំណង....





To book a reservation call @
PHONE 215-462-0886 / Cell 215-833-3669

ពេលម៉ោងបើកទ្វារពីម៉ោង ៤-៨ ល្ងាច ក្នុងមួយសប្តាហ៍ ហើយពីម៉ោង ១០-០៤ ល្ងាច សំរាប់ថ្ងៃសៅរ៍ ចុះតម្លៃ ពិសេស សំរាប់ធ្វើដំណើរទៅកាន់អាស៊ីអគ្នេយ៍

We're accepted all methods of payment. We're very Proud to serve you for the last 11 years, and your business with is highly appreciated


តមកពីទំព័រទី ០៣

# សន្និសីទពិភាក្សាស្តីពីនៅសាទីយ៉ុង...

ស្រុកខ្មែរ(នៅក្នុងកណ្តាប់ដៃយួន) មិនអាចត្រឡប់ ទៅក្រោយវិញបាន" ដូចការប្រកាសរបស់ ផាំ យ៉ាំង ដុង ដែលជានាយករដ្ឋមន្ត្រីយួនហាណូយ នាពេល នោះ ។

**នៅសតវត្សទី២០ យួនធ្វើខ្លួនជាខ្មែរ**

តាមការពិត គំនិតយួនធ្វើខ្លួនជាខ្មែរ បានកើត ឡើងតាំងពីឆ្នាំ១៩៣០ នៅពេលដែល ហូជីមិញ និង ក្រុមសមមិត្តគាត់ បានបង្កើត"បក្សកុម្មុយនីស្តឥណ្ឌូ ចិន" ដោយអះអាងថាជាបក្ស តំណាងប្រជាជនយួន ប្រជាជនលាវ និងប្រជាជនខ្មែរ ។ ប៉ុន្តែនាពេលនោះ បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលមានសមាជិកស្ថាបនិក ចំនួន ២១១នាក់ វាគ្មានមួយនាក់សោះ ដែលមាន កំណើតជាលាវ ឬជាខ្មែរ ។ ក្នុងទសវត្ស១៩៤០ អ្នក ដឹកនាំសំខាន់ៗ នៃចលនា "ខ្មែរ-យៀកមិញ" ដែល ប្រយុទ្ធដែរ ដើម្បី "ឯករាជ្យនៅកម្ពុជា" គឺ សឺន ង៉ុក មិញ និង សឺវ ហេង ដែលមានកំណើតជាយួន ។ កង ឯកភាពរបស់ខ្មែរ-យៀកមិញ នៅភូមិភាគអគ្នេយ៍ នៃកម្ពុជា មានទាហានយួនជាភាគធំណាស់ ចំណែក ឯខាងខេត្តបាត់ដំបងវិញ វាមានសុទ្ធតែទ័ពយួនតែ ម្តង ។ ម្យ៉ាងទៀត នាខែមីនា ១៩៥០ នៅក្នុងការ ប្រជុំមួយរបស់យៀកមិញ និងក្រុម "ខ្មែរឥស្សរៈ" មេយៀកមិញធំម្នាក់ មកពីស្រុកយួនឈ្មោះ ង្វៀង ថាន់សឺន បានបញ្ជាថា ពួកអន្តោសប្រវេសន៍នៅកម្ពុជា ត្រូវមានតួនាទីជា "កម្លាំងម៉ាស៊ីន នៃការកសាង ចលនាបដិវត្តនៅកម្ពុជា"។

មកដល់ឆ្នាំ ១៩៥៤ នៅក្នុងសន្និសីទ នាក្រុង ហ្សឺណែវ ស្តីពីឥណ្ឌូចិន រដ្ឋាភិបាលយួនហាណូយ បាន ទាមទារឱ្យគេទទួលស្គាល់ពួកយៀកមិញ-ខ្មែរទាំង នោះ និងការកាត់ទឹកដីខ្មែរមួយចំណែកឱ្យពួកនោះ កាន់កាប់។ ដោយហេតុគេមិនយល់ព្រម ពួកយៀក-មិញទាំងនោះ ក៏ត្រូវគេបង្ខំឱ្យដកខ្លួនចេញពីស្រុក ខ្មែរ ។ ការពិត តើពួកទ័ពយៀកមិញ និងអន្តោ-ប្រវេសន៍យួន (ដែលជា"កម្លាំងម៉ាស៊ីន"នយោបាយ របស់គេ) ប៉ុន្មាននាក់ ដែលក្រាញលាក់ខ្លួននៅកម្ពុជា ជាបន្តទៅទៀត ? នៅសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៦៩) ពួកនាយទាហានខ្មែរ បានឱ្យដឹងថា កម្លាំងយួនកុម្មុយនិស្ត នៅតែមានតាំងទីជានិច្ចក្នុង ជាយដែនខេត្តរតនគីរី មណ្ឌលគីរី និងស្ទឹងត្រែង។ នៅឆ្នាំ១៩៨២ ហ៊ុន សែន (ដូច្នេះគឺក្រុងហាណូយ ដែរ) បានអះអាងថា ជនជាតិយួននៅកម្ពុជា "នា មុនឆ្នាំ ១៩៦៩ មានចំនួនជាង ៥០០.០០០ នាក់" គឺ លើសសឹងតែ ២ដង លើចំនួនប្រមាណរបស់រដ្ឋា ភិបាលខ្មែរ និងរបស់អ្នកស្រាវជ្រាវបរទេស នាពេលនោះ។ ហ៊ុន សែន បានអះអាងទៀតថា ជន ជាតិយួនទាំងនោះ បានធ្វើការងារ "នៅក្នុងចំការ កៅស៊ូ ក្នុងស្រែចំការ ក្នុងរោងចក្រ ក្នុងទន្លេ និងប-ឹង ទន្លេសាប ជាកម្មករ ជាកសិករ ជាអ្នកនេសាទ ជា អ្នកចិញ្ចឹមសត្វ ។ល។ ដើម្បីជួយចំរុងចំរើនដល់ សេដ្ឋកិច្ចកម្ពុជា ។ លុះមានការសង្កាត់សង្កិននៃពួក សក្តិភូមិ ពួកអាណានិគមនិយម និងពួកចក្រពត្រ និយម ពួកវៀតណាមទាំងនោះ បានរួបរួមជាមួយ ក្រុមជនជាតិទាំងអស់នៅកម្ពុជា ក្នុងការប្រយុទ្ធ ដើម្បីឯករាជ្យជាតិ សេរីភាព និងដើម្បីកិច្ចសាង សង់ និងការពារមាតុភូមិរបស់ពួកគេ"។

**ពួក"អន្តោប្រវេសន៍" យួនថ្មី ពីឆ្នាំ១៩៧៩**

យើងបានដឹងហើយថា ពីឆ្នាំ១៩៧០-១៩៧៥ (សង្គ្រាមរវាងយួនកុម្មុយនីស្ត / ខ្មែរក្រហម និងខ្មែរ សាធារណរដ្ឋ) រួចមក ពីឆ្នាំ១៩៧៥-១៩៧៩ (របប ខ្មែរក្រហម) ជនជាតិយួនស៊ីវិល បានចេញអស់ពីស្រុក ខ្មែរ។ ប៉ុន្តែក្រោយពីថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ភ្លាម ចលនា"អន្តោប្រវេសន៍"យួនមួយថ្មី បានចូលមក កម្ពុជាទាំងហ្វូងៗដូចទឹកជំនន់ តាមក្រោយការវាយ ប្រហារ និងបានកាន់កាប់ខេត្ត-ក្រុងខ្មែរ នៃកងទ័ព យួនកុម្មុយនីស្ត ។ ក្នុងពេលដំបូងពួកមេខ្មែរដែល ចូលដៃនិងយួន ក៏ភ្ញាក់ផ្អើលយ៉ាងខ្លាំងដែរ ។ ហេង ស៊ិរន ដែលជានាយករដ្ឋមន្ត្រី ចាត់តាំងបានចេញសា រាចរ ចុះថ្ងៃទី ១៩ តុលា ឆ្នាំ ១៩៨០ ឱ្យពួកគេចាប់ បញ្ជូនយួនទាំងនោះទៅវៀតណាមវិញ ព្រោះថា "បងប្អូន(វៀតណាម) ទាំងនោះមិនធ្លាប់នៅទីនេះ ទេ...គឺសុទ្ធជាជនអន្តោប្រវេសន៍ខុសច្បាប់"។ លុះ ចាន់ស៊ី ឡើងធ្វើជានាយករដ្ឋមន្ត្រី គាត់បានយល់ ព្រមនៅក្នុងសារាចរចុះថ្ងៃទី៩ តុលា ឆ្នាំ ១៩៨២ ឱ្យ យួនចូលមកធ្វើអាណានិគមនៅស្រុកខ្មែរតាមអំពើ ចិត្ត ដោយស្របតាម"សេចក្តីសម្រេចចិត្តនៃលេខា ធិការដ្ឋាននៃគណៈមជ្ឈិមរបស់បក្ស"ចុះហត្ថលេខា ដោយ សាយ ភូថង ។ គឺជាការសម្រេចចិត្តដោយ គេអះអាងថា "ប្រជាជនទាំងពីរ (យួននិងខ្មែរ) ត្រូវបានផ្សាសាច់ឈាមជាមួយគ្នា ដោយការប្រយុទ្ធ ទល់និងសត្រូវរួម ដើម្បីការពារ និងសាងសង់ប្រទេស យើងទាំងពីរ" ហើយ។

នៅថ្ងៃទី២០ កក្កដា ១៩៨៣ ហ៊ុន សែន បាន ស៊ីញ៉េជាបន្ថែមទៀតជាមួយ ង្វៀង កឺ ថាច់ នូវ"កិច្ច ព្រមព្រៀងស្តីពីលក្ខន្តិកៈនៅតាមព្រំដែន"មួយដែ ល បើកចំហព្រំដែន ឱ្យពួកអាណានិគមយួនចូលមក កម្ពុជាដោយសេរី។ គេបើកច្រកចូលចំនួន៨ គឺលើ ផ្លូវជាតិ(ខ្មែរ) លេខ១ លេខ២ លេខ៧ លេខ១៣ លេខ ១៤ លេខ ១៧ លេខ១៨ និងលើទន្លេមេគង្គ ។ បន្ទាប់មកហ៊ុន សែន បានបញ្ជាក់នៅក្នុងការផ្សាយ នៅក្រសួងគាត់ថា "ពួកវៀតណាម និងក្រុមគ្រួសារ ដែលធ្លាប់មករស់នៅក្នុងកម្ពុជា ត្រូវបានអនុញ្ញាត ឱ្យទៅកាន់កាប់ទីលំនៅ និងប្រកបការងាររបស់ខ្លួន ពីពេលមុនជាថ្មីវិញ" តែគេមិនបានអនុញ្ញាតដូចគ្នា នេះឱ្យជនជាតិខ្មែរទេ។ នៅខែមករា ១៩៨៥ ហ៊ុន សែន បានឡើងថ្នាក់ជានាយករដ្ឋមន្ត្រី។ នៅថ្ងៃទី២៦ កុម្ភៈ ១៩៨៦ គាត់បានចេញសារាចរបញ្ជាក់ជាថ្មី អំពី ស្ថានភាពនៃពួក"អន្តោប្រវេសន៍" យួនថ្មីថា "ការ អនុវត្តបទណែនាំនៃសារាចរនានា ពីឆ្នាំ ១៩៨២ ពុំ មានល្បឿនសមតាមការកំណត់នៃរដ្ឋបាលយើងទេ ហើយពុំមានលទ្ធផលសមតាមការគ្រោងទុកមកទេ ជាអាទិ៍ក្នុងការផ្តល់ទីលំនៅ ការងារ និងអត្តសញ្ញាណ-ប័ណ្ណ (ឱ្យពួកវៀតណាម ទាំងនោះ)។"ហេតុនេះ ហ៊ុន សែន សម្រេចឱ្យបក្ស និងរដ្ឋ ព្រមទាំងប្រជាជនខ្មែរ "ទទួលបង-ប្អូន វៀតណាមយ៉ាងរាក់ទាក់បំផុត ដោយ

តទៅទំព័រទី ១៦

# A.B.C MONEY TRANSACTION, INC

# $ ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |



សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

**8 locations to serve you in Virginia**

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

### ARIZONA

◆4215 N 19th Ave. . Tel : 602.266.6744

### GEOERGIA

◆ 4897 Buford Hwy. Ste. 202. Tel: 770.457.7888

### ILLINOIS

◆4871 N. Broadway . Tel :773.989.7332

### MASSACHUSETTE

◆ 996 Dorchester Ave. Tel:617.825.9380

◆ 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

### MINNESOTA

◆ 2718 Nicollet Ave . S.- Ste. 102 B

◆ Tel : 612.871.4731

◆ 6350 Brooklyn Blvd . Tel : 763.503.3947

### NORTH CAROLINA

◆ 3000 Central Ave. Ste . #9 . Tel : 704-532-4420

### OREGON

◆6908 N.E. Sandy Blvd . Tel : 503.281.8088

### PHILADFELPHIA

◆5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794

◆571 Adams Ave . Ave.#4 . Tel : 215.342.6623

### TEXAS

◆1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461

◆2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817

◆5302 E . Belknap St.- Ste.D6 . Tel : 817.831.4836

◆3538 W . Walnut St. Tel : 972.272.2253

◆11205 Bellaire Blvd . Tel : 281.561.6600

◆10909 Scarsdale Blvd . Tel : 281.481.2700

◆13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

### WASHINTON STATE

◆766 S.38th St,. Tel : 253.475.2847

◆3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776

Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

តមកពីទំព័រទី ០១

# ស្វាគមន៍ឆ្នាំ ២០១០...

ដែល មហាត្ថ័កគន្ធី នៅពេលកំពុងបង្រួបបង្រួមប្រជាជាតិ ទាមទារឯក?រាជ្យជូនប្រទេសឥណ្ឌា បានពិពណ៌នាអំពីតួនាទីកាសែតប្រាប់ ញូយ៉កថែម ថា "កាសែតនិងបង្រួបបង្រួមមនុស្ស ហើយនាំមកនូវសន្តិភាព"។ រាត្រីទី១ មករា នោះ សន្តិភាពបានកើតឡើងយ៉ាងពិតប្រាកដដោយម្នាក់នៅពេលចូលអង្គុយតុ តាមលំដាប់លេខរៀង សុទ្ធតែមានចាត់ជាក្រុមជាពួក តែដល់ពេលចេញទៅវិញ បានបង្ហាញនូវសំណើចនូវភាពរីករាយជាមិត្តជាកន ជាគ្រួសារភ្លេចអស់នៃរនាំងនៃទំនាក់ទំនងដែលមានពីមុនមក។ លើសពីនោះទៅទៀត ម្នាក់បាននាំយកទៅដំណេកវិញ នូវអនុស្សាវរីយ៍នៃភាតរៈភាព រវាងចាស់និងជំនាន់ ក្មេង នៅការវិញកម្លាំងគ្នានៃក្រុមអតីតយោធា និងក្រុមបច្ចុប្បន្នជាស៊ីវិល នៅការមិនចែកគ្នាជាបក្សសម្ព័ន្ធនយោបាយ ឬសាសនា ជាពិសេសចូលរួមយ៉ាងភ្លេចខ្លួននៅក្នុងចំណងដៃសិល្បៈដែលម្នាក់ មានដក់នៅក្នុងព្រលឹងដូចៗគ្នា វប្បធម៌រួមគ្នា ដែលម្នាក់បានឱ្យតម្លៃ



ភ្ញៀវច្រៀងជូនពរខួបកំណើតជូនព្រឹទ្ធាចារ្យ



នាកសិស្សបោះបង់សាលារៀបរៀងដោយ ម៉ម យីន រួមសំដែងដោយ សរិត ប៉ែន និង អ៊ឹម លឿង



អតីតយុទ្ធជនស្ម័គ្រចិត្ត ៤រូប ធ្វើសច្ចាប្រណិធាន



យាយ ផាន់ រៀបការនាងទាវ

ខ្ពង់ខ្ពស់ទៀតផង។

កម្មវិធីនៃរាត្រីទី១របស់ឆ្នាំ២០១០ បានផ្តើមដោយការបំពាក់ស័ក្តិរបស់អតីតយុទ្ធជនស្ម័គ្រចិត្តខ្មែរ៤រូប ដោយលោក ថាច់ ម៉ារិន មេបញ្ជាការ និងលោក ម៉ម យីន ជាឧត្តមទីប្រឹក្សា បង្ហាញពីរូបភាពទទួលស្គាល់អតីតកាល ប្រកបដោយវីរភាពរបស់អតីតយុទ្ធជនខ្មែរ ។ អតីតយុទ្ធជនខ្មែរ ប្រមាណ ៣០នាក់ ដែលបានទទួលឋានន្តរស័ក្តិជាផ្លូវការរួចហើយ បានមកអបអរសាទរដល់យុទ្ធមិត្តរបស់ខ្លួនយ៉ាងពេញចិត្តក្នុងពិធីការណ៍ចលនាយោធា ដែលពុំដែលមានពីមុនមក។

ណែនាំដោយពិធីករ ពិន សំខុន និង រឿម ឡុង ភ្ញៀវកិត្តយសនារាត្រីនោះ បានឡើងមកជូនពរនិងថ្លែងសុន្ទរកថាខ្លីៗ ដល់សហគមន៍ខ្លួនម្នាក់ម្តងៗ មានសមាគមខ្មែរតំណាងដោយលោក សរិត សម មានតំណាងឱ្យសមាគមខ្មែរកម្ពុជាក្រោម, មានលោក មាស ជា តំណាងគណបក្ស សម រង្ស៊ី និងចាស់ទុំថ្នាក់ដឹកនាំមួយចំនួនទៀត ដែលនៅបន្តសកម្មភាពណែនាំបង្រួបបង្រួមសហគមន៍ ដូចជាលោក ចាន់វង្ស អៀប, លោក អ៊ូ កៅ, លោក អ៊ូ គឹមហ៊ួត បានមកសម្តែងមតិនារាត្រីនោះដែរ ។

លោក ម៉ម យីន ក្នុងតួនាទីនៃស្នេហ៍ខ្មែរប៉ុស្តិ៍ម្នាក់ បានលើកកំណាព្យសិស្សបោះបង់សាលាចូលរួម ដោយតួយុវជន អ៊ឹម លឿម និងយុវជន សរិត ប៉ែន បានធ្វើឱ្យភ្ញៀវខ្លះភិតភ័យស្ទើររត់ចោលបុណ្យ ទម្រាំដឹងថា ទង្វើនេះជាឆាកល្ខោនសោះ សំណើចក៏បានផ្ទុះឡើងនៅចុងបញ្ចប់ ។

ថែមពីលើនេះទៀត លោក គឹម ភឿន ស្នេរ ម្នាក់ទៀត បានលើកល្ខោនរឿងទុំទាវមកសម្តែង បន្ទាប់ពីបានថ្លែងយ៉ាងអស់សង្ឃឹមថា "ល្ខោន យើងខ្ញុំទើបតែនឹងហាត់បានបីម៉ោង"។ តែទោះជាហាត់ពេលខ្លីក្តីសម្តែងចម្រៀងយីកេដ៏ក្រលូចរបស់យាយ ផាន់ (ដោយនាងភ័ក្រ្ត) និងទំនួញនាងទាវ (នាងវ៉ានី) បានធ្វើឱ្យភ្ញៀវភ្លឹកស្មារតីនិងទេពកោសល្យសម្តែងដ៏ខ្ពស់នេះ ជាពិសេសចម្រៀងល្ខោនបាសាក់របស់ទុំ (ដោយលោក សរិត ប៉ែន) ដែលពេជឃាតសម្លាប់មិនព្រមស្លាប់ (ដោយវិសាកា) បានធ្វើឱ្យទស្សនិកជន ធ្លាយសំណើចផង ទឹកភ្នែកផង ដោយមិននឹកស្មានថា ហ្វីឡាដែល-ហ្វៀ សំបូរដោយសិល្បករកម្រិតខ្ពស់យ៉ាងនេះសោះ។

សន្តិភាពដែលសហគមន៍ខ្មែរដ៏តូចមួយទទួលបាននារាត្រីថ្ងៃទី១ មករា នោះ គឺប្រាកដជាពុំមែន ការបញ្ចប់នៃសង្គ្រាម ដែលចេះតែលងប្រជាជាតិខ្មែរនោះទេ -នាទីនោះពុំមានសង្គ្រាមទៀតទេ ពុំមានការគម្រាមឱ្យនរណាខ្លាចទៀតទេ ក៏ប៉ុន្តែយើងពុំដែលមានឱកាស ឬបរិយាកាសណាមួយ ដើម្បីពង្រឹងសន្តិភាពក្នុងខ្លួនជាបុគ្គល ដូចថ្ងៃទី១ មករាកន្លងទៅនោះទេ ។ យើងតែងតែនាំគ្នាដុតនូវកំហឹង ឱ្យកាន់តែឆេះធ្លោធំទៅៗ ដែលធ្វើឱ្យការពិចារណាត្រឹមត្រូវចេះតែថយថយ ហើយទទួលបាននូវលទ្ធផលចុងក្រោយ គឺ "អំនួត" តែប៉ុណ្ណោះ ។ មហាត្ថ័តគន្ធី បានព្យាយាមប្រើសន្តិវិធី ដែលជាកម្លាំងដ៏ខ្លាំងក្លាសម្រាប់បណ្តេញបរទេសឈ្លានពានចេញពីឥណ្ឌា រហូតដល់បានសម្រេច ។ គឺ គន្ធី នេះឯងដែលបានបង្ហាញ "សន្តិភាពផ្លូវចិត្ត" ដែលបង្កើតជាសង្គ្រាមចិត្តសាស្ត្រដ៏ខ្លាំងក្លានៅក្រោមអំណាចហិង្សានៃចក្រភពអង់គ្លេស ដោយប្រើថាមពលគន្លឹះ គឺ "មិនព្រមទទួលច្បាប់ចិនបរទេសនៅលើទឹកដីឥណ្ឌា" ។

ហូជីមិញ បានយកគម្រូនេះ ដើម្បីបណ្តេញអាមេរិកាំងចេញពីវៀតណាម ម៉ាតាំង លូទ័រឃីង ក៏បានយកទ្រឹស្តីដដែលនេះ មករំដោះពលរដ្ឋអាមេរិកាំងស្បែកខ្មៅ ពីទាសភាព "សន្តិភាពចិត្តរបស់ម្ចាស់ស្រុក"បានបង្ករទំនាស់យ៉ាងឆ្លាតវៃ ហើយបានបើកមុខអ្នកឈ្លានពានឱ្យបង្ហាញសាធារណជនជាស្វ័យប្រវត្តិឱ្យបញ្ចេញក្រឡាសារខិលខូចរបស់ខ្លួននៅកណ្តាលវាល ។ នៅគ្រប់ដំណាក់ការណ៍នៃព្រឹត្ត-ិការណ៍ទាំងនោះ គេឃើញវត្តមានអ្នកសារព័ត៌មានដ៏មានប្រយោជន៍សម្រាប់ពួកគេជានិច្ច ។

ឆ្នាំ២០១០ ផ្តើមក្នុងបរិយាកាសសន្តិភាពរបៀបនេះ ជាសញ្ញានៃការប្រែប្រួលដ៏សំខាន់មួយ នៃសហ-គមន៍ខ្មែរ នៅហ្វីឡាដែលហ្វៀ និងឆ្នេរខាងកើតយ៉ាងប្រច័ក្ខ ។ ព្រឹត្តការណ៍ "សន្តិភាព" នេះបានកើតឡើងដោយចៃដន្យមែន តែពេញមួយសប្តាហ៍បន្តមក អ្នកដែលចូលរួមទូរស័ព្ទស្វែងរកគ្នាសម្តែងការអបអរ និងកោតសរសើរគ្នាទៅវិញទៅមកយ៉ាងខ្នាត់ខ្នែង ហើយខ្លះមានគម្រោងចង់ធ្វើសកម្មភាពរួមគ្នាទៅអនាគតដ៏វែងឆ្ងាយទៀតផង ។ ខ្មែរប៉ុស្តិ៍ពុំដឹងថា តើបំណងល្អទាំងនោះនឹងទៅដល់ឆ្ងាយប៉ុណ្ណាទេ...ក៏ប៉ុន្តែបើបំណងល្អថ្មីនេះ ធ្វើទៅបាន គឺជាការផ្លាស់ប្តូរទៅរកភាពសច្ចៈយ៉ាងថ្មីស្រឡាង មួយដោយសហគមន៍ខ្លួនឯង ដូច្នេះការផ្លាស់ប្តូរឯទៀតប្រាកដជានឹងកើតឡើងបានដូចគ្នា ដូចជាការប្រយុទ្ធនឹងភាពក្រីក្រ, ភាពអវិជ្ជា, អំពើហិង្សាក្នុងសង្គមបាន....។

រាត្រីនោះ ខ្មែរប៉ុស្តិ៍ បានជូនរង្វាន់ដោយការចាប់ឆ្នោតវត្ថុអនុស្សាវរីយ៍ ដែលបានមកពីអំណោយពាណិជ្ជករ ដែលតែងតែជួយឧបត្ថម្ភដំណើរការណ៍កាសែត, បានមកពីតំណាងនៃសហគមន៍ខ្មែរជាច្រើន

តទៅទំព័រទី ១៩



តមកទំព័រទី ០៤

# គឹម សុខា នៅហ្វីឡាដែលហ្វៀ....

ជូនដល់ភ្ញៀវអ្នកស្តាប់វិញម្តង ដែលមានខ្លឹមសារសំខាន់ៗដូចជា "រំលឹកពីកម្ពុជា កំពុងរំកិលមកដល់មាត់ជ្រោះគ្រោះថ្នាក់យ៉ាងគួរឱ្យបារម្ភ ថាមិនអាចត្រឡប់ថយក្រោយវិញបានឡើយ ប្រសិនបើគណបក្សប្រជាធិបតេយ្យនៅកម្ពុជា ទាំងអស់មិនអាចរួមគ្នាជាធ្លុងមួយបានទេនោះ" ។ ការគ្រោះថ្នាក់នោះសំដៅទៅរកអ្នកដឹកនាំផ្នែកនយោបាយកម្ពុជា កំពុងបំរើផលប្រយោជន៍នៃប្រទេសវៀតណាម ដោយគ្មានលាក់លៀម ហើយបង្កគ្រោះថ្នាក់សង្គ្រាមជាមួយនឹងប្រទេសថៃ ។ វាគ្មិនជាច្រើនបានឡើងចាប់អារម្មណ៍ ហើយតាំងសំនួរអំពីសម្ព័ន្ធភាពជាមួយគណបក្ស សម រង្ស៊ី ជាពិសេស



សមាជិកសំខាន់ជួបលោក គឹម សុខា



វិសាកាពេជ្រ ភរិយា និងលោក គឹម សុខា

ថ្កោលទោសចំពោះចលនាថ្ងៃ៧ មករា ដែលថាជាថ្ងៃនៃការរស់រានមានជីវិត ជាលើកទីពីរ រីឯកាតពិតវាគ្មិន នាំគ្នានិយាយពីជ័យជំនះនៃវៀតណាមទៅវិញ។

ទស្សនៈកិច្ចរបស់លោកប្រធានគណបក្សសិទ្ធិមនុស្ស នៅហ្វីឡាដែលហ្វៀ បានបន្តនៅថ្ងៃបន្ទាប់មកនៅវត្តព្រះពុទ្ធរង្សី ស្ថិតនៅផ្លូវ រីតន័រ និងផ្លូវលេខ៦ នៃហ្វីឡាខាងត្បូង លោកបានជួបថ្វាយបង្គំព្រះសង្ឃ ប្រគេនចង្ហាន់ ហើយជួបសំណេះសំណាលជាមួយពុទ្ធបរិស័ទដែលមកចូលរួមធ្វើបុណ្យនាព្រឹកថ្ងៃអាទិត្យ បន្ទាប់មកនោះរួចលោកបានបើកធ្វើសន្និសីទព័ត៌មានមួយក្នុងនាមជាប្រធានគណបក្សនយោបាយផង និងជាតំណាងរាស្ត្រខ្មែរ នៅសាលប្រជុំរបស់វត្ត នាវេលារសៀល ដោយមានភ្ញៀវប្រមាណ ៣០នាក់ ចូលរួមក្នុងនោះ



គឹម សុខា ជួបជាមួយនឹងសហព័ន្ធខ្មែរកម្ពុជាក្រោម

មានភ្ញៀវកិត្តិយសមាន ៣ នាក់ ដែលជាអតីតសមាជិកសភា និងព្រឹទ្ធសភាចូលរួមផង គឺលោក រស់ ហ៊ាន, លោក ប្រាក់ វ៉ានី និងលោក ស៊ិន ប៊ូ ។ ក្នុងរយៈពេល ២ ម៉ោង វាគ្មិន បានផ្តោតទៅលើបញ្ហាបយោបាយបន្តិចបន្តួច តែប្រមូលការតាំងសំនួរជាច្រើនទៅលើសម្ព័នភាពអ្នលប្រជាធិបតេយ្យ ដើម្បីស្វែងរកការឈ្នះឆ្នោតសភាជាតិ ឆ្នាំ ២០១៣ លើគណបក្សប្រជាជនកម្ពុជា ដែលវាគ្មិន និយាយថាជាគណបក្សកុម្មុយនីស្ត រណបឱ្យបរទេសវៀតណាម ។

នៅថ្ងៃអង្គារ ១២ មករា លោក គឹម សុខា និងធ្វើទស្សនៈកិច្ចនៅ រីកម៉ុន រដ វៀជីនៀ បន្ទាប់មកមកជួបជុំពលរដ្ឋខ្មែរ នៅរដ្ឋធានី វ៉ាស៊ីនតុន មុននឹងបន្តដំណើរទៅទីក្រុង យូស្តុន រដ្ឋតិចសាស់ ទៀត៕

*ខ្មែរប៉ុស្តិ៍*


# DRANOFF ASSOCIATES
*Attorneys at Law*

"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE ) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះដែលមានរបួសរូវាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍៣៥ឆ្នាំ ធ្វើជាតំណាងឱ្យឯកជន ដែលពុំមែនឱ្យក្រុមហ៊ុន ឬក្រុមធានារ៉ាប់រងទេ ។



យើងធានាថា ផ្តល់គុណភាពសេវាច្បាប់យ៉ាងខ្ពស់ ហើយយកចិត្តទុកដាក់ ជាពិសេសដល់អតិថិជនរបស់យើង ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យ - បានន័យថា លោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វី មុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្បាញ៉ុល ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

សូមអញ្ជើញទូរស័ព្ទមកពេលនេះភ្លាមចុះ ដើម្បីពិគ្រោះសម្ងាត់ដោយមិនគិតថ្លៃ ឬក៏អញ្ជើញមកជួបនៅការិយាល័យយើងក៏បាន ។

DRANOFF ASSOCIATES

121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com



# Danny's Café




Foods & Hoagies

1. Beef Stew Serve with Bread..............................
2. Curry Chicken Serve with Bread........................
3. Curry Beef Saramann Serve with Bread.................
4. Meatball Soup Serve with Bread ......................
5. Mi Siam ................................................





1730 Snyder Ave, Philadelphia, PA 19145 / Mon – Fri: 7am – 7pm Saturday: 9 am – 8 pm / Sunday : CLOSED
Tel: 215.467.4082 Fax: 215.467.4642 / Thank You, Please come again !

# តារាចម្រៀង ម៉េង ពេជ្ជតា ប្រមូលទ្រព្យសម្បត្តិ មុនពេលតុលាការសម្រេចឱ្យបែកផ្លូវ



នាង ម៉េង ពេជ្ជតា

**ដោយ : ពេជ្រ បណ្ឌូល**

ដោយនៅរង់ចាំការសម្របសម្រួលជាលើកទី៣ តាមច្បាប់រដ្ឋប្បវេណី ក្នុងបណ្ដឹងសំលែងលះរបស់តារាចម្រៀងស្រី ម៉េង ពេជ្ជតា នោះ តុលាការក្រុងភ្នំពេញ ពុំទាន់ចាត់វិធានការទៅលើសំណុំរឿងព្រហ្មទណ្ឌ ដែលតារាចម្រៀងរូបនេះ រូបនឹងបងស្រីបង្កើតប្ដឹងលោក មួង ឃីម ដែលជាស្វាមីនៅឡើយទេ ។ ប៉ុន្តែជាមួយគ្នា នាង ពេជ្ជតា បានធ្វើការរឹបអូសរួចស្រេចទៅហើយ នូវរថយន្តលុចស៊្សស (Lexus) មួយគ្រឿង និងផ្ទះ ដែលគេដឹងថា ភាគច្រើនជាលុយ មួង ឃីម នោះ ។



លោក មួង ឃីម នាង ម៉េង ពេជ្ជតា និងកូន

យោងតាមប្រភពពីមន្ត្រីតុលាការក្រុងភ្នំពេញ ឱ្យដឹងថា នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ខាងមុននេះ តុលាការបានកោះហៅនាង ម៉េង ពេជ្ជតា និងលោក មួង ឃីម ឱ្យធ្វើការផ្សះផ្សាជាលើកទី៣ ក្នុងសំណុំរឿងលែងលះ ដែលនាង ម៉េង ពេជ្ជតា ប្ដឹងសុំលែងលះលោក មួង ឃីម ជាស្វាមី ។ ហើយបើការផ្សះផ្សានោះ ត្រូវទទួលបរាជ័យ តុលាការនឹងលើកយកទៅកាត់ក្ដីជាសាធារណៈ ហើយបន្ទាប់មកចាត់ការទៅលើសំណុំរឿងព្រហ្មទណ្ឌ ។ សំណុំរឿងព្រហ្មទណ្ឌដែលត្រូវបាននាង ពេជ្ជតា និងបងស្រីឈ្មោះ កែវ ពេជ្របុប្ផា បានប្ដឹងលោក មួង ឃីម ក្រោមបទបង្ករបួសស្នាម និងរំលោភលើលំនៅដ្ឋាន ។

បណ្ដឹងព្រហ្មទណ្ឌនេះ បានកើតឡើងបណ្ដាលមកពីមានហេតុការណ៍ប្រតាយប្រទប់គ្នាមួយឈុតកាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ ខណៈដែលលោក មួង ឃីម បានទៅផ្ទះរបស់ឈ្មោះ ម៉េង កែវពេជ្របុប្ផា មានទីលំនៅក្នុងខណ្ឌដង្កោ ដើម្បីយកកូនសោផ្ទះពីប្រពន្ធ ប៉ុន្តែពេលទៅដល់ផ្ទះ ប្អូនរបស់នាង ពេជ្ជតា បានរារាំង ហើយបានប៉ះទង្គិចគ្នាដោយកម្លាំង ដែលនាង ពេជ្ជតា បានទទួលរង់គ្រោះថ្នាក់បន្តិចបន្តួច ។

លោក មួង ឃីម ដែលមានឋានៈជាឧត្ដមសេនីយក្រសួងមហាផ្ទៃ ធ្លាប់បានថ្លែងប្រាប់អ្នករាយការណ៍ព័ត៌មានថា មូលហេតុដែលឈានទៅដល់ការបែកបាក់គ្នារវាងលោក និងភរិយា គឺបណ្ដាលមកពីភាពមិនស្មោះត្រង់ និងការជួយជ្រោមជ្រែងពីក្រុមគ្រួសារនាង ពេជ្ជតា ។

ជុំវិញសំណុំរបស់តារាចម្រៀងល្បីល្បាញឈ្មោះរបស់កម្ពុជានេះ គេមើលឃើញថា លោក ឃីម ទីបំផុតអាចនៅត្រឹមតែខ្លួនទទេរ ឬក៏ត្រូវឈានទៅដល់ថ្នាក់ជាប់ពន្ធនាគារទៀតផង ៕




777-300ER

## ពីញូយ៉កទៅតាយប៉េ ហោះ ៤ ជើងក្នុងមួយសប្ដាហ៍

ចាប់ផ្ដើមហោះហើរពីថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៩ //
"អេវ៉ា" អាកាសចរមានសេវា ញូយ៉ក-តាយប៉េ នៅថ្ងៃច័ន្ទ ថ្ងៃពុធ-ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍...ធ្វើឱ្យដំណើរទៅកាន់ទ្វីបអាស៊ីមានភាពប្រសើរគ្មានពេលណាដូចយន្តហោះថ្មីធុន ជាមួយនឹងបន្ទប់ធំទូលាយ និងមានបច្ចេកទេសទំនើបចែកជាថ្នាក់អ្នកដំណើរទី១ ថ្នាកអ្នក់ដឹកនាំ និងថ្នាក់អ្នកដំណើរមធ្យម មានបន្ទប់បុគ្គលិកគួរឱ្យចូលចិត្ត សម្រាប់បង្កើនបរិយាកាសសម្រាកកាយ និងកក់ក្ដៅក្នុងចិត្ត ធ្វើឱ្យដំណើរលោកអ្នករីតតែរីករាយប្រសើរឡើង ។






EVA AIR

EVA Wings – Booking, Buying and Bonuses just a click away at www.evaair.com

Contact us at our local service hotline: 800-695-1188


HONG KONG
SUPERMARKET
FAMER´S BEST
$1.69/can
$3.49 each
Newly Renovated.
Added new section .
Clean and Improved
management !
ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត
ឋាងស្អាត ហើយបង្កើន
គុណភាពគ្រប់គ្រង
Weekly Sale
លក់ចុះថ្លៃរៀងរាល់សប្តាហ៍
$2.99/bag
$7.99
$2.99
$6.99/box
$1.29/can
$2.49/28oz
$2.49/bag
2 for $3
$4.99 / lb
OPEN
7 DAY
8:00-9:00
571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-7281300 Fax: 215-728-1600
• ចំណាយ $140ដុល្លារ ទទួលបានអង្ករស្រូវស ២៥ ផោន
• ចំណាយ $100ដុល្លារ ទទួលបាននូវភេសជ្ជៈ ឬទឹកញ្ចប់មួយប្រអប់(តម្លៃ8.99)
• ចំណាយ $25 ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

ឌឹ ខេមបូឌា ដេលី
The Cambodia Daily

ជំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទបានអនុញ្ញាតិឱ្យធ្វើការចុះផ្សាយដោយ ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី០៨ ខែមករា ឆ្នាំ២០១០

# Ruling Party Celebrates Jan 7 Warns Critics

By Frank Radosevich and Phorn Bopha
THE CAMBODIA DAILY

CPP members and a crowd of thousands gathered yesterday at the party's Phnom Penh headquarters, where party President Chea Sim feted the 31st anniversary of the fall of the Khmer Rouge while cautioning others against criticizing the politically charged public holiday.

Mr Chea Sim, who is also Senate president, marked the celebration with a speech praising the victory over the Pol Pot-led government, brought about through support from the Vietnamese armed forces, which lead the charge into Phnom Penh on Jan 7, 1979.

"The people of Cambodia remember always that January 7 is their second date of birth, because if it were not for January 7, there would be no life and present conditions," Mr Chea Sim told an audience sporting matching white hats and shirts displaying the CPP logo.

The ruling party's leader also chided those who oppose the day's celebration, noting "a few people have always assigned themselves as enemies of the January 7 victory while taking actions that are contrary to the principles of democracy and the rule of law...all in the aim of preventing the country's progress."

Though the country was liberated from the Khmer Rouge regime on Jan 7, 1979, the decade-long Vietnamese occupation that lasted until 1989 has led those who oppose the CPP to remember the day as the beginning of a foreign invasion by an historic foe.

Mr Chea Sim also praised the work of the Extraordinary Chambers in the Courts of Cambodia but

Continued on page 18

# គណបក្សកាន់អំណាចប្រារព្ធទិវា៧មករា ហើយប្រមានអ្នករិះគន់

ដោយ Frank Radosevich និង ផន បុប្ផា
THE CAMBODIA DAILY



ក្រុមសមាជិកគណបក្សប្រជាជនកម្ពុជានិងក្រុមមនុស្សរាប់ពាន់នាក់បានជួបជុំគ្នានៅទីស្នាក់ការគណបក្សនេះនៅក្នុងទីក្រុងភ្នំពេញកាលពីម្សិលមិញ ទីដែលលោក ជា ស៊ីម ប្រធានគណបក្សបានចូលរួមជាកិត្តិយសនៃខួបលើកទី៣១នៃការដួលរលំរបបខ្មែរក្រហម ទន្ទឹមគ្នានោះដែរបានព្រមានអ្នកដទៃទៀតចំពោះការរិះគន់ថ្ងៃបុណ្យជាតិដែលគេគិតថា មានលក្ខណៈនយោបាយ ។

លោក ជា ស៊ីម ដែលជាប្រធានព្រឹទ្ធសភាផងដែរបានប្រារព្ធពិធីនេះជាមួយនិងការថ្លែងសុន្ទរកថាសរសើរពីជ័យជម្នះលើរបបដែលដឹកនាំដោយ ប៉ុល ពត ដែលសម្រេចបានតាមរយៈការគាំទ្រពីកងទ័ពវៀតណាមដែលបានចូលមកទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករាឆ្នាំ១៩៧៩ ។

តទៅទំព័រទី ១៨

ការិយាល័យថែទាំសុខភាពគ្រួសារ
5746 Rising Sun Avenue. Philadelphia, Pa 19120
Phone: (215)904-6891 Fax: (215) 745-2290
DR. TRUONG H. NGUYEN, M.S., D.O., P.C
FAMILY MEDICINE – INTERNAL MEDICINE – OSTEOPATHIC MANIPULATIVE THERAPY
វេជ្ជបណ្ឌិតជំនាញខាងព្យាបាលជម្ងឺទឹកនោមផ្អែម_សរសៃបេះដូង_ពិនិត្យសុខភាពស្ត្រី (GYN)
_ពិនិត្យតម្រងនោម_ប្រព័ន្ធរំលាយអាហារ...
* ផ្នែកពិនិត្យសុខភាពជាប្រចាំ និងព្យាបាលជម្ងឺស្បែក....ឈឺក្បាលប្រកាំង, ឈឺសន្លាក់ដៃជើង
បញ្ជាក់សុខភាពសម្រាប់អាពាហ៍ពិពាហ៍, សម្រាប់ធ្វើដំណើរ និង សម្រាប់សាលារៀន
* ជាពិសេស : ទទួលព្យាបាលអ្នកគ្រោះថ្នាក់មានមុខរបួស ឬរអិលដួលនៅកន្លែងធ្វើការ
យើងណែនាំផ្តល់មេធាវីដែលមានបទពិសោធន៍ជាង ២០ ឆ្នាំ និងអ្នកបកប្រែភាសាជំនាញ មានខ្មែរ-ចិន-វៀតណាម
ជូនដោយឥតគិតថ្លៃ បើលោកអ្នកត្រូវការ :
* ធានាថា យើងធ្វើការបានលទ្ធផលឆាប់រហ័ស-លើសពីនេះ យើងរីករាយនឹងជួយដល់ភ្ញៀវណាដែល
មិនចេះនិយាយអង់គ្លេស ហើយចង់កំណត់ពេលទៅមន្ទីរពេទ្យ ឬចង់ប្តូរ
ក្រុមហ៊ុនធានាសុខភាព (Health Insurance)
* យើងទទួល មេឌីកេដ,មេឌីឃែ , និង អ៊ិនសួរិន ស្ទើរតែទាំងអស់
និងគិតតម្លៃទាបជូនអ្នកដែលមិនមាន អ៊ិនសួរិន ទៀតផង ។
ការិយាល័យបើកទ្វារ :៣
ថ្ងៃ ច័ន្ទ -អង្គារ-ពុធ- និង សុក្រ
ពីម៉ោង ៩ព្រឹកដល់១រសៀល
និងពីម៉ោង ៣ ដល់ ៧ ល្ងាច
បិទទ្វារ : ថ្ងៃ សៅរ៍ និងថ្ងៃអាទិត្យ និងព្រហស្បតិ៍

# ខ្មែរមានពូជ

តពីលេខមុន

*•••វាគ្មិនបួនរូប បានរៀបចំសិក្ខាសាលាមួយ នៅវត្តពោធិវង្ស នៃប្រទេសបារាំង ដើម្បីសិក្សារកឫសគល់ ដែលចេះតែនាំឱ្យខ្មែរ ឱនភាពផ្នែកស្មារតី តាំងពីបន្ទាប់សម័យអង្គរមក ។ ចំណោមអ្នកទាំងបួននោះ ក៏មានព្រះសង្ឃមួយអង្គផងដែរ ព្រះនាម ងិន កេន, លោកវេជ្ជបណ្ឌិត ស៊ុយ សៀងហេង, លោក ឌី ការ៉េត និង លោក ចាយ សេរីវុឌ្ឍ កាលពីថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៩ ។ វត្តពោធិវង្ស 101 BOULEVARD DELA REPUBLIQUE 77420 CHAPS SUN MARNE-FRANCE ។ ខ្មែរប៉ុស្តិ៍ បានលើកយកប្រយោគជាសេចក្តីរាយការណ៍របស់អ្នកទាំងបួន មកអានជាសណ្តាប់ ដោយយល់ថា ភាពឱនខ្សោយនៃស្មារតីខ្មែរ នាពេលនេះ នៅតែជាកង្វល់របស់សាធារណជនស្ទើរគ្រប់ៗគ្នា ។ សូមអញ្ជើញអាននូវប្រយោគរបស់អ្នកទាំងបួន ដែលធ្វើវិភាគជូនសហគមន៍ខ្មែរជាច្រើននៅប្រទេសបារាំងដូចតទៅ :*



## លោក ស៊ុយ ស៊ាងហេង ឧមត្ថុ វតនត្ថយស្ស

(២) - លោហិតវិជ្ជា = ការសិក្សាខាងឈាម ។

គេក៏ឃើញមានជាតិ ហេមោគ្លោប៊ីន-អ៊ី (Hb-E) នៅត្រង់នោះដែរ គឺនៅក្នុងព្រំដែននៃមហានគរខ្មែរ នាសតវត្សទី១១(៣) នោះឯង ។

**តើ ហេមោគ្លោប៊ីន_អ៊ី ជាអ្វី ?** គឺជាជាតិពណ៌ក្រហម នៅក្នុងគុលិកាឈាមក្រហម ។ ហេមោគ្លោប៊ីន ជាថង់ដាក់អុកស៊ីនស្វែន Oxygén ជញ្ជូនទៅចិញ្ចឹមកោសិកានៅសព្វសារពាង្គកាយ (ឈាមពណ៌ក្រហមស្រស់) ។ លុះពេលត្រឡប់មកសួតវិញ **ហេមោគ្លោប៊ីន** នេះក៏ស្រូបយកឧស្ម័នកាបូនិច (Co²) ដែលជាកាកសំណល់នៃកោសិកា ត្រឡប់មកចោលក្នុងសួតវិញ (ឈាមពណ៌ក្រហមក្រម៉ៅ) សំណល់នេះនឹងចាកចេញទៅក្រៅខ្លួនយើងនៅគ្រប់ដង្ហើម ។

**ហេមោគ្លោប៊ីន_អ៊ី** Hb-E ? គឺជា

គឺជា **ហេមោគ្លោប៊ីន** មិនធម្មតា (ដុះខ្នែងថ្មី) **ហេមោគ្លោប៊ីន** មិនធម្មតាជាច្រើនបានកើតឡើងពីដំណើរប្រែប្រួល(៤) យ៉ាងរហ័សនៃរចនា-

(៣) - នេះជាសេចក្តីសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ ស្ហង់ បាកណា Pr. Jean BERNARD (1907-2009) ។

(៤) - តាមភាពប្រែប្រួល = ដោយប្រការផ្សេងៗ មានធាតុអាកាស, ចំណីអាហារ, ព្យាធិ, រដូវ, សកម្មភាព, ។ល។ ជីវិត (មនុស្ស សត្វ រុក្ខជាតិ និងវត្ថុ) ក្នុងលោកនេះ សុទ្ធតែវិវឌ្ឍន៍ទៅរកភាពប្រែប្រួលជានិច្ច មានខ្លះប្រែប្រួលតាមទម្លាប់ធម្មតា ឯខ្លះទៀត (ភាគតិច) ខុសពីធម្មតា ដូចករណី **ហេមោគ្លោប៊ីន-អ៊ី** នេះឯង ។ នេះក៏ជាច្បាប់ធម្មជាតិដែរ ។ ច្បាប់នេះមិនអនុញ្ញាតឱ្យនរណា ឬក្រុមណាឱ្យនៅបានដោយ មិនបាច់ផ្លាស់ប្តូរ (ទីកន្លែង ចិត្តគំនិត រាងកាយ) នោះទេ អ្នកដែលមិនគោរពច្បាប់នេះ ទោះជាទម្រន់ក្តី ភ្លេចភ្លាំងក្តី ត្រូវតែវិនាសមុនគេជានិច្ច ដោយជម្ងឺក្រិន (រាងកាយ ឬ គំនិត) ។

សម្ព័ន្ធនៅក្នុងកោសិកាឈាមក្រហម ។ ក្នុងចំណោមមនុស្សដែល **ហេមោគ្លោប៊ីន** ប្រែប្រួលយ៉ាងនេះ លទ្ធផលដែលហុចឱ្យគឺ **ហេមោគ្លោប៊ីន** ខ្លះនាំជម្ងឺមកឱ្យគុលិកាឈាមក្រហម អាយុខ្លី ។ តែ **ហេមោគ្លោប៊ីន** ខ្លះទៀត មិនរុករកសុខភាពមនុស្សទេ មាន **ហេមោគ្លោប៊ីន_អ៊ី** Hb-E ជាអាទិ៍ ជនទាំងនេះអាចរស់ដូចគេឯងជាធម្មតា ។ **ហេមោគ្លោប៊ីន** មិនធម្មតាផ្សេងទៀត គឺមាន **ហេមោគ្លោប៊ីន** C.D.E.S ។ **ហេមោគ្លោប៊ីន_អ៊ី** (Hb-E) ចាប់មានក្នុងឈាមប្រជាជនខ្មែរ នាសតវត្សទី១០ និងទី១៣ គ.ស ពេលដែលមហារដ្ឋកម្ពុជា កំពុងរីកធំពេញទំហឹង (ដែនដីនោះ លាតសន្ធឹងនៅលើវាលទំនាប និងដែនដីសណ្ត នៃទន្លេមេគង្គ ប្រទេសឡាវ ប្រទេសសៀម ភាគខ្លះនៃប្រទេសម៉ាឡេស៊ី និងវៀតណាមសព្វថ្ងៃនេះ) ។ នៅតំបន់ទាំងនោះ គេឃើញមានបូជនីយដ្ឋាន(៥) ជាច្រើន ជាអាទិ៍ គឺនៅតំបន់អង្គរ និងក្រៅព្រំដែន នៃប្រទេសខ្មែរសព្វថ្ងៃនេះ ។ ផែនទីនៃភូមិសាស្ត្រ **ហេមោគ្លោប៊ីន_អ៊ី** និងភូមិសាស្ត្រនៃបូជនីយស្ថាន សិល្បៈខ្មែរ ស្ទើរតែដូចគ្នាបេះបិទ គឺថា

***តទៅលេខក្រោយ***



## ដោយ : ឌី ការ៉េត

នៅដើមសម័យ ហ្វូណន ពួកអ្នកដំណើរចិន បានឃើញថា (ខ្មែរ ជាជាងទង (ធ្វើគ្រឿងមាស-ប្រាក់) យ៉ាងប៉ិនប្រសប់ ចេះត្បាញសំពត់យ៉ាងល្អប្រណីត ជាអ្នកចេះកែខៃទឹកដីយ៉ាងចំណានដើម្បីកសិកម្ម ចេះធ្វើសំពៅដើរសមុទ្រ មានប្រវែង ៣០ ម៉ែត្រ..." ។

នៅសម័យ ហ្វូណន (ឬ នគរភ្នំ( ចិនឡា និង អង្គ បច្ចេកកសិកម្ម សំណង់ ចម្លាក់ និងសិល្បៈផ្សេងៗ បានចំរើនជាខ្លាំងទៀត ដោយសារខ្មែរ បានស្រង់យកគំនិតស្មារតី និងចំណេះវិជ្ជាពីឥណ្ឌា ប៉ុន្តែដោយរក្សាចរិតដើមនៃជាតិសាសន៍ខ្លួនជានិច្ច ។ ខ្មែរពូកែខាងវិទ្យាសាស្ត្រ ជាពិសេសគណិតវិទ្យា រូបវិទ្យា តារាវិទ្យា និងសំណង់ ។ ខ្មែរបានបង្កើតរបៀបរាប់លេខនព្វន្ធ ដែលមានមូលដ្ឋានប្រាំ (១,២,៣,៤,៥) ហើយបំបែបដល់លេខដប់ ។ ក្នុងវិស័យអក្សរសាស្ត្រ និងសិល្បសាស្ត្រ បានបង្កើតកំណាព្យ និងចំរៀងជាច្រើនបែបបទ ហើយតន្ត្រី និងរបាំខ្មែរ មានឈ្មោះល្បីល្បាញឆ្លងប្រទេស ឆ្លងជាតិសាសន៍ ឆ្លងសតវត្សមកដល់សព្វថ្ងៃ ។ រីឯវិជ្ជាធ្វើម្ហូបខ្មែរ ក៏ជាស្នាដៃយ៉ាងធំមួយទៀត ដែលត្រូវបានជនជាតិឯទៀតរៀនធ្វើតាមរហូតមកដល់ ។

### ប្រពៃណីខ្មែរ នៃការអប់រំខ្មែរ

ទេពកោសល្យទាំងនេះ បានបង្កើតមានដោយសារជនជាតិខ្មែរចូលចិត្តរៀនសូត្រវិជ្ជា ហើយមានស្មារតីផ្ចិតផ្ចង់ការងារណាស់ ។ នៅសម័យ ហ្វូណន ក្នុង គ.ស. ទី៣ យើងបានដឹងថា មានឯកសារជាច្រើនណាស់ ស្តីអំពីវិជ្ជា និងការងារផ្សេងៗ ដែលគេរក្សាទុកក្នុងបណ្ណាល័យនានា ។ នៅក្នុងលទ្ធិព្រាហ្មណ៍សាសនា គេរៀនសូត្រច្រើនបំផុត អំពីគម្ពីរ "វេទ" (Les Vedas) ជាភាសាសំស្ក្រឹត ដែលនៅក្នុងនោះ មានវិជ្ជាសព្វយ៉ាង ជាអាទិ៍ គឺសាសនា អក្សរសាស្ត្រ វេយ្យាករណ៍ ច្បាប់ (នៃអាទិទេព) វេជ្ជសាស្ត្រ គណិតសាស្ត្រ តារាសាស្ត្រ ស្ថាបនកម្ម សេដ្ឋសាស្ត្រ កសិកម្ម នយោបាយ សង្គ្រាមសាស្ត្រ និងសិល្បសាស្ត្រ ឬបច្ចេកទេសផ្សេងៗទៀត ។ ការចេះដឹងរបស់អ្នកប្រាជ្ញខ្មែរ នាសម័យនោះ បានលេចឮទៅទីឆ្ងាយៗណាស់ ។ នៅសតវត្សទី៣ ប្រទេសចិន បាននិមន្តមហាភិក្ខុខ្មែរ ខាងពុទ្ធសាសនាជាច្រើនអង្គ ឱ្យទៅបង្ហាត់បង្រៀនព្រះពុទ្ធសាសនា នៅប្រទេសគេ ។ ក្រោយមកទៀត ចិនបាននាំយកអ្នកតន្ត្រីខ្មែរ ឱ្យទៅសំដែង និងបង្ហាត់បង្រៀនពួកអ្នកតន្ត្រីគេដែរ ។ នៅក្រុងអង្គរ មានពួកអ្នកប្រាជ្ញពីឥណ្ឌា និង ជ្វា មកសិក្សានៅសាកលវិទ្យាល័យខ្មែរ ជាបន្តបន្ទាប់ ។ នៅសម័យនោះ ស្រីខ្មែរ ក៏មានចំណេះវិជ្ជាខ្ពង់ខ្ពស់ មិនចាញ់ប្រុសទេ ។

នៅសម័យក្រោយៗមកទៀត ខ្មែរក៏តែងតែអប់រំកូនចៅខ្លួន ក្នុងគោលការណ៍ធំៗពីរ ជានិច្ច កូនស្រី-ប្រុស :

១-ត្រូវយល់ថា ចំណេះវិជ្ជា ជាប្រវត្តិនៃទ្រព្យសម្បត្តិ និង ឫទ្ធានុភាព ហេតុនេះ គេត្រូវខំស្វែងរកចំណេះវិជ្ជាជានិច្ចកាល ។ ***តទៅលេខក្រោយ***



## ចាយ សេរីវុឌ្ឍ

និងទម្រង់ទ្រឹស្តីសាសនាថ្មី ដោយគំនិតផ្ទាល់ខ្លួន ព្រមទាំងបង្កើតឈ្មោះ ឋានៈ និងតួនាទីនៃអាទិទេព ភាពជាក្សត្រិយ៍ បព្វជិត ឱ្យមានជាឋានានុក្រមផ្សេងៗ ដែលមានលក្ខណៈច្បាស់លាស់ជាងនៅក្នុងឋានានុក្រមឥណ្ឌា ទៅទៀត ។

ម្យ៉ាងទៀត ក្នុងការសាងសង់បូជនីយដ្ឋាន ឬវិហារ ព្រមទាំងរូបចម្លាក់ លោក ហ្សង់ ហ្វីលីយូស្ហាត់ បានកំណត់សំគាល់ថា ខ្មែរបានធ្វើ តាមលំនាំរបស់ឥណ្ឌាមែន ប៉ុន្តែខ្មែរចេះឆ្លាក់ រចនាបញ្ចេញភាពត្រចះត្រចង់ប្លែកពីឥណ្ឌាទាំងអស់ ។ យើងមិនដែលឃើងបូជនីយដ្ឋានខ្មែរណាមួយបញ្ជាក់ប្រាប់ថា ពីការចម្លងចម្លាក់ផ្ទាល់របស់ឥណ្ឌាទេ ។

លោក ហ្សាក់ ឌុយម៉ាសៃ (Jacques Dumarcay)(២) ដែលសិក្សាអំពី "ប្រាជ្ញារួមគ្នានៃប្រជាជន"

(២) - Intelligence collective et architecture en Asie du Sad-Est, par Jacques Damarcay, in, *Annales HSS*, mai-juin 1998, n°3, pp.505-535

បានពន្យល់ថា ការកសាង វិមាន ប្រាសាទ ឬក៏ធ្វើរូបចម្លាក់ ក្រុមអ្នកបច្ចេកទេសខ្មែរ បានទៅរកគំរូពីប្រទេសឥណ្ឌាមែន ។ ប៉ុន្តែវិមានដែលលោកបានឃើញ គឺមានលំអគ្រប់ទិដ្ឋភាព ដូចជា ប្រាសាទបក្សីចាំក្រុង ដែលខ្មែរបានកសាងឡើង ក្នុងសតវត្សទី៩ ។ ចាប់តាំងពីសតវត្សទី១០មក ខ្មែរទាំងអស់នោះ ក៏បានក្លាយទៅជាគ្រូខ្លួនឯង ពីព្រោះបានយល់ច្បាស់លាស់ ពីបច្ចេកទេសនៃការសាងសង់ ។ ភស្តុតាង គឺប្រាសាទតាកែវ ឬប្រាសាទប្រែរូប ដែលខ្មែរបានកសាងដោយលើកកំពស់ឱ្យខ្ពស់បាន ដោយមិនចាំបាច់ផ្លាស់ប្តូររូបរាងនៃផែនការសំណង់ទេ ។

ពីសតវត្សទី១០ ទៅសតវត្សទី១២ ប្រទេសខ្មែរ មិនបានជួបប្រទះពីបញ្ហាសេដ្ឋកិច្ចទេ ព្រោះបច្ចេកទេសនៃសំណង់ទំនប់ទឹក បានឡើងកំរិតយ៉ាងខ្ពស់ មានទឹកប្រើប្រាស់គ្រប់វិស័យ ធ្វើឱ្យកសិកម្មផ្តល់ភោគផលជាអតិបរមា ។ ភោគផលទាំងអស់នោះ ជាអាហារ ដែលជាជំនួយដល់ការសាងសង់វិមាន និងប្រាសាទនៃព្រះរាជាណាចក្រខ្មែរ ជាច្រើនឥតឈប់ឈរ ។

ចំពោះលោក ហង់រី ម៉ារសាល់ (Henri Marchal)(៣)

(៣) - L´indépendence de I´art khmer visávis de I´art indien par Henri Marchal, Consercvateur d´Angkor, in. Revue des Arts asiatiques, III° Année, n°4, Décembre 1926, pp.173-179.

វិញ គឺការធ្វើរូបចម្លាក់របស់ខ្មែរ និងរបស់ឥណ្ឌា មានភាពមិនដូចគ្នាទេ ។ របៀបឆ្លាក់រូបសត្វ រូបយក្ស ឬរូបទេវតា ខ្មែរបានយកតាមឥណ្ឌាមែន ប៉ុន្តែគំនិត និងគោលដៅក្នុងការឆ្លាក់រូបទាំងនោះ គឺខុសពី ឥណ្ឌាស្រឡះ ។ ចម្លាក់ខ្មែរប្លែកពីគំរូចម្លាក់ឥណ្ឌាទាំងអស់ ។

### ២- ការរៀបចំប្រទេសខ្មែរ :

តាមឯកសារចិន តាំងពីសតវត្សទី៥មក ស្រុកខ្មែរមានឈ្មោះថា "ហ្វូណន" ។ ***តទៅលេខក្រោយ***



## ភិក្ខុ ងិន កេន ឥន្ទប្បញ្ញោ

ព្រះបាទជ័យវរ្ម័នទី៧ មានព្រះទ័យអាណិតអាសូប្រជានុរាស្ត្រខ្លាំងណាស់ ទុក្ខរបស់រាស្ត្រ គឺទុក្ខរបស់ព្រះអង្គ...។ សូម្បីតែសត្វ ក៏ព្រះអង្គអាណិត អាសូដែរ មានរហូតដល់សាងមន្ទីរពេទ្យព្យាបាលរោគសត្វទៀតផង ។ ព្រះអង្គតាំងព្រះទ័យនឹងសាងប្រទេសខ្មែរ ឱ្យទៅជាស្ថានសួគ៌ សាងប្រជាជនខ្មែរឱ្យទៅជាទេវតា...។ មិនមែនគិតរត់ចោលស្រុកមនុស្សទៅរកស្រុកទេវតា ដូចបុគ្គលខ្លះកាន់សាសនាជ្រុលហួសនោះទេ ។ ពូជខ្មែរព្រហ្មបាយ័ន កូនខ្មែរត្រូវតែយកព្រហ្មវិហារធម៌ មកបដិបត្តិក្នុងជីវិតប្រចាំថ្ងៃវិញឱ្យបាន។

**៤-ពូជខ្មែរព្រះខាន់ :** ព្រះបាទជ័យវរ្ម័នទី ៧ បានសាងប្រាសាទព្រះខាន់ មិនមែនក្នុងគោលបំណងសាងព្រះខាន់ ឬតម្កល់ទុកនូវព្រះខាន់ជារូបធាតុ (ដែក) នោះទេ ។ សេចក្តីពិត ព្រះអង្គចង់សាង ព្រះខាន់ផ្លូវធម៌ គឺបញ្ញាភ្លឺស្វាង ដឹងខុស ដឹងត្រូវ ដឹងខាត ដឹងចំណេញ...ចេះគ្រប់គ្រងខ្លួន ចេះកាត់ផ្តាច់កិលេសគឺឈ្នះនូវអំពើអាក្រក់របស់ខ្លួនជាដើម ។ បុគ្គលដែលមានបញ្ញាជាព្រះខាន់បែបនេះ ទើបអាចសាងសេចក្តីសុខដល់ខ្លួន ដល់អ្នកដទៃ និងដល់ប្រទេសជាតិបាន។ អាស្រ័យហេតុនេះទើបព្រះអង្គហ្វឹកហាត់មនុស្សជាពិសេស អ្នកដឹកនាំប្រជាជនឱ្យ គេនាំគ្នាបដិបត្តិសមាធិ (សីល សមាធិ បញ្ញា) ដើម្បីយកសេចក្តីសុខចំរើនតាំងពីក្នុងជីវិតបច្ចុប្បន្ននេះទៅ មិនមែនរំលងចោលនូវប្រយោជន៍ក្នុងជាតិនេះ ហើយចាំទទួលផលប្រយោជន៍ឋានសួគ៌ ឬព្រះនិព្វាននោះទេ ។ នេះហើយជាពូជខ្មែរព្រះខាន់ ជាពូជដ៏ប្រសើរវិសេស ដែលកូនខ្មែរគ្រប់គ្នាត្រូវតែមានបញ្ញា កុំចង់រស់តែឯង...កុំចាញ់បោកបរទេស ។

**៥-ពូជខ្មែរអ្នកបួស :** តាមប្រវត្តិសាស្ត្រតំណាលថា ព្រះបាទអសោកមហារាជ ព្រះអង្គជាកំពូលអគ្គពុទ្ធសាសនូបត្ថម្ភក៍ ក្នុងជម្ពូទ្វីប ។ ព្រះអង្គត្រាស់សួរថា ព្រះអង្គបានទំនុកបម្រុងពុទ្ធសាសនា ច្រើនយ៉ាងនេះ តើបានជាញាតិក្នុងពុទ្ធសាសនាហើយឬនៅ? ព្រះមោគ្គលីបុត្ត តិស្សត្ថេរថ្វាយព្រះពរថា ព្រះអង្គមិនទាន់បានជាញាតិទេ ព្រោះព្រះអង្គមិនទាន់បានទ្រង់ព្រះផ្នួស ឬមិនទាន់បានបំបួសព្រះរាជបុត្រាបុត្រីនៅឡើយ ។ អាស្រ័យហេតុនេះទើបព្រះបាទអសោក ទ្រង់បំបួសព្រះរាជបុត្រ គឺព្រះមហិន្ទ និងព្រះរាជបុត្រី គឺព្រះសង្ឃមិត្តា ដែលក្រោយមកបានជាសមណទូត ទៅប្រកាសពុទ្ធសាសនា នៃប្រទេសសិរីលង្កា ជាភស្តុតាងស្រាប់។

ខ្មែរយើងចាប់តាំងពីកាន់ពុទ្ធសាសនាមក ក៏បានអនុវត្តន៍តាមប្រពៃណីនេះ តាំងពីសម័យនគរភ្នំរៀងរហូតមក ។ នៅប្រាសាទនគរវត្តថ្នាក់កណ្តាល ក៏មានចារិតរឿងព្រះមហាក្សត្របំបួសព្រះរាជបុត្រនេះដែរ ។ ប៉ុន្តែចាប់តាំងពីសម័យបារាំងចូលគ្រប់គ្រងប្រទេសកម្ពុជាមក ខ្មែរយើងចាប់សាបរលាបរឿងបួសនេះរឿយៗរហូតមក។ ឥឡូវយើងត្រូវតែបដិបត្តិឱ្យបានល្អឡើងវិញ។ ***តទៅលេខក្រោយ***

តមកពីទំព័រទី ០៤

# សន្និសីទពិភាក្សាស្តីពីទិវា ៧ មករា...

ចែករំលែកមធ្យោបាយរស់នៅ មានផ្ទះសម្បែង ដីធ្លី ផលិតផលផ្សេងៗ ។ល។ ឱ្យបង-ប្អូនទាំងនោះផង "។ ទោះយ៉ាងនេះក្តី គេបានដឹងថា សារាចរ និងកិច្ចព្រមព្រៀងនានា គ្រាន់តែជាដីកា"ជាផ្លូវការ"របស់ពួកខ្មែរនោះ ដើម្បីបញ្ជាក់ និងធ្វើឱ្យមានលក្ខណៈ "ស្របច្បាប់"នូវអំពើរំលោភរបស់យួន នៅលើទីកន្លែងជាស្រេចមកហើយប៉ុណ្ណោះ។

**រដ្ឋបាលពីទន្ទឹមគ្នា**

ការពិត គឺពួកអាណានិគមយួនថ្មី បានមកតាំងទីតាមតែគេប្រាថ្នា ដោយបានទទួលកិច្ចការពារនៃកម្លាំងយួនដែលកាន់កាប់កម្ពុជា ជាបឋម គឺនៅកន្លែងយុទ្ធសាស្ត្រ និងតំបន់មានភោគទ្រព្យច្រើនទាំងអស់។ បន្ទាប់ពីខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ ពួកនេះបានចូលមកយ៉ាងរហ័សដល់ក្រុងភ្នំពេញ និងនៅលើមាត់ទន្លេសមេគង្គ ទន្លេបាសាក់ (តាំងពីក្រុងអ្នកលឿន ដល់ក្រុងកំពង់ចាម) លើបឹងធំទន្លេសាប និងលើដងស្ទឹងនានា ដែលនាំចូលទៅក្នុងប្រទេសទៀត។ ភាគធំបំផុត នៃពួកអាណានិគមយួនថ្មី ជាយុវជនដែលគ្មានគ្រួសារជាមនុស្សអាវ៉ាសែ ចូលមកផ្សងព្រេងវាសនា និងមានចរិកភ្លើតភ្លើន និងប្រមាថមើលងាយប្រជាជនខ្មែរណាស់ ។ គេអួតអាងប្រាប់ខ្មែរៗថា គេជា"អ្នកមករំដោះពួកឯង(ខ្មែរ)ឱ្យបានរួចពីរបប ប៉ុល ពត" ឱ្យខ្មែរទាំងអស់យល់ថា គេមានសិទ្ធិគ្រប់យ៉ាងនៅលើទឹកដីដែលគេវាយយកបាននោះ។

ចំណុចសំខាន់មួយ គឺពួកអាណានិគមយួននេះ មានសិទ្ធិធ្វើស្រែចំការ ជាហេតុធ្វើឱ្យកសិករខ្មែរ មិនសប្បាយចិត្តសោះ និងមានសេចក្តីបារម្ភជាខ្លាំង ។ កាលពីសម័យមុនឆ្នាំ១៩៧០ គេធ្លាប់បានឃើញពួកយួននៅស្រុកខ្មែរ ប្រកបការងារជាកសិករ ជាអ្នកនេសាទ ជាអ្នកជំនួញមែន ប៉ុន្តែគេសឹងតែមិនដែលប្រទះ និងយួនធ្វើស្រែចំការទេ។ នៅពេលនេះវិញ គេស្រាប់តែឃើញយួនចូលមកធ្វើស្រែនៅស្រុកខ្មែរ នៅតាមខេត្តជាច្រើនកន្លែងដែលមានដីជាតិល្អ ។ ម្យ៉ាងទៀត ពួកកសិករយួនទាំងនេះ មិនត្រូវបង់ពន្ធអាករអ្វីទេ និងថែមទាំងមិនត្រូវជាប់កំណែនធ្វើទាហាន និងកំណែនទៅកាប់ស្កាព្រៃនៃកិច្ចប្រតិបត្តិការ"ក ៥ "ដែលអាជ្ញាធរបានដាក់បញ្ញត្តិ បង្ខំដល់ប្រជាជនខ្មែរទាំងអស់នោះទេ ។ នៅឯខាងទីក្រុងវិញ គេឃើញមានតែកម្មករយួន ដែលជាជាងសំណង់ ជាងភ្លើង ជាងឈើ ជាងធ្វើកង ឬជាងម៉ាស៊ីនផ្សេងៗ ។ល។ ត្បិតយុវជនខ្មែរត្រូវគេចាប់ប្រមូលឱ្យទៅច្បាំង ឬទៅការងារចម្បាំងក្នុងព្រៃភ្នំទប់ទល់និងកម្លាំងតស៊ូខ្មែរដែលប្រឆាំងនិងយួន។

ជាទូទៅពួកអាណានិគមយួនមិនរស់នៅលាយឡំជាមួយនិងប្រជាជនខ្មែរទេ ។ គេរស់ផ្តុំគ្នា ជាភូមិសង្កាត់យ៉ាងខ្ជាន់ខ្ជាប់ ដែលអ្នកមិនមែនយួន មិនងាយចូលចុះទេ ។ ភ្នាក់ងារនគរបាលខ្មែរ នាសម័យនោះ បានឱ្យយើងដឹងថា "ពួកយួនគ្រប់គ្រងភូមិ-សង្កាត់គេ ដោយខ្លួនគេ បង្កើតការលក់ដូរដោយខ្លួនគេ រៀបចំសន្តិសុខដោយខ្លួនគេ ដោះស្រាយទំនាស់ផ្សេងៗដោយខ្លួនគេទាំងអស់..."។ ដូច្នេះគេមានអ្នកអភិបាល មានប៉ូលិស មាន"មន្ទីរកាត់ក្តី" របស់គេនៅគ្រប់កន្លែង។ ភូមិ-សង្កាត់នោះសោត តែងតែរីកធំជាលំដាប់ ដោយគេតែងតែទទួលពួក គេដែលមកដល់ថ្មីៗទៀតជាហូរហែ ។ បើគេមានទំនាស់ជាមួយនិងខ្មែរ គេប្តឹងទៅអាជ្ញាធរយួនដែលកាន់កាប់នៅទីនោះ ឱ្យដោះស្រាយបញ្ហា



របស់ពួកគេ ជាមួយអាជ្ញាធរខ្មែរ ជំនួសគេ ។ ជាបន្ថែមពួកយួនជាច្រើន បានដាក់ឈ្មោះខ្លួនជាខ្មែរ (តែគេប្រើឈ្មោះយួនជាមួយគ្នីគ្នាគេជានិច្ច) ហើយខំហាត់រៀននិយាយភាសាខ្មែរ។ អ្នកដែលចេះភាសាខ្មែរគ្រាន់ បើទោះជាមិនចេះអក្សរក្តី ត្រូវបានអាជ្ញាធរយួន យកឱ្យកាន់តំណែងសំខាន់ៗនៅក្នុងរដ្ឋបាលនៃទីក្រុង និងតាមខេត្តផ្សេងៗនៃកម្ពុជា ។

យើងឃើញថា ពួកអាណានិគមយួនបានធ្វើតាមរូបភាពនៃពួកអាណានិគមបារាំងសម័យមុន ដោយបង្កើតរដ្ឋបាលពីទន្ទឹមគ្នា គឺមួយសម្រាប់ការត្រួតត្រាកម្ពុជា មួយទៀតសម្រាប់ការពារប្រយោជន៍របស់យួនជាគ្នីគ្នាគេ ។ ប៉ុន្តែវាមាន"លក្ខខណ្ឌ"មួយដែរ ដែលពួកយួននៅស្រុកខ្មែរនេះត្រូវទទួលគឺពួកគេមិនអាចវិលទៅរស់នៅស្រុកយួនវិញកើតទេ (ពីព្រោះបញ្ហាសំបុត្រស្នាម) ហើយក្រុងហាណូយ សុខចិត្តធ្វើអ្វីៗទាំងអស់ដើម្បីសម្រួលជីវភាពនៃយួនទាំងនេះ ឱ្យបានរស់នៅចាក់ឫសរឹតតែជ្រៅនៅកម្ពុជា ។

**ការទទួលស្គាល់អាណានិគមយួនជាផ្លូវការ**

ថ្ងៃ៧មករា ១៩៧៩ ពិតជាថ្ងៃមហាជោគជ័យថ្មីនៃអាណានិគមនិយមយួន។ ពាក្យថា ជា"ការរំដោះ" ប្រជាជន គឺជាពាក្យមួយដែលពួកអាណានិគមនិយម/ចក្រពត្រនិយមបានប្រើគ្រប់កាលសម័យ និងនៅគ្រប់ទិសទីក្នុងលោក ហើយមានន័យជាប្រវត្តិសាស្ត្រត្រឹមតែជាការរំលំរបបសាហាវឃោរឃៅមួយ ដោយដាក់របបបរទេសនោះមកជំនួស ដែលគេអួតអាងថា វាមានលក្ខណៈជា "បដិវត្តន៍ពិតប្រាកដ" និងមាន "ប្រជាធិបតេយ្យ" ជាងមុន ប៉ុន្តែវាមានគោលដៅដូចគ្នា គឺការសង្កត់សង្កិនលើប្រជាជនក្នុងស្រុកដែលត្រូវបានអ្នកមុនកំទេចឱ្យទ្រុឌទ្រោមជាស្រេចហើយ ។

ក្នុងបញ្ហាកម្ពុជា បន្ទាប់ពីសន្ធិសញ្ញាក្រុងប៉ារីសចុះឆ្នាំ១៩៩១ ស្តីពីកម្ពុជា ពួកអាណានិគមយួននៅតែចូលមកទាំងហ្វូងៗជានិច្ចកាល តាមគ្រប់រូបភាពដោយមានកិច្ចការពារនៃបក្សប្រជាជនកម្ពុជារបស់ហ៊ុន សែន ។ ចលនាសម្ព័ន្ធនៃការចាំទទួលនិងការរៀបចំទុកដាក់ពួកនេះ មិនត្រូវបាននរណាកំចាត់បង់ទេ តែផ្ទុយទៅវិញគេពង្រឹងនិងពង្រីកវាឱ្យរឹតតែមាំមួន និងធំថែមទៀត ដោយរដ្ឋាភិបាល ហ៊ុន សែន ទទួលស្គាល់ជាផ្លូវការតែម្តង។ ឧទាហរណ៍ធំមួយ គឺការប្រកាសតំបន់ "ត្រីកោណអភិវឌ្ឍន៍" ដោយ ហ៊ុន សែន ម្នាក់ឯ ជាមួយនិងក្រុងហាណូយ នាខែតុលា ១៩៩៩ (ក្រោយពីរដ្ឋប្រហារបង្ហូរឈាម នាខែកក្កដា ១៩៩៧) គ្រាន់តែជាការទទួលស្គាល់ ជាផ្លូវការជាថ្មីដល់កិច្ចអាណានិគមយួន នៅខេត្តធំៗខ្មែរ រតនគិរី និងមណ្ឌលគិរី ដែលមានប្រជាជនខ្មែរ រស់នៅបន្តិចបន្តួច ។ ក្រុងហាណូយបានបញ្ជាក់ជានិច្ចថា *"ត្រីកោណនេះ ជាតំបន់យុទ្ធសាស្ត្រមួយសំខាន់* (សម្រាប់ប្រទេសវៀតណាម) *ក្នុងវិស័យនយោបាយ* (គឺការពារប្រទេស និងសន្តិសុខ) *សង្គមកិច្ច និងសេដ្ឋកិច្ច* (សម្រាប់បញ្ចូលពួកអាណានិគមយួនបន្ថែមទៀត ឱ្យមកកាន់កាប់ដីធ្លីសម្បទានរាប់សែនហិកតា ពីរដ្ឋាភិបាល ហ៊ុន សែន" ។ បន្ទាប់មកគេបានពង្រីកបរិវេណ "ត្រីកោណ" ហ្នឹង មកដល់ខេត្តស្ទឹងត្រែង ហើយនឹងពេលថ្មីៗនេះដល់ក្រចេះទៀត ។ ការពិត គឺពួកយួនបានរុលចូលដល់ខេត្តកំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ រហូតដល់កោះកុង និងកំពង់សោម ពាសពេញទៅហើយ តាមរូបមន្ត "សហប្រតិបត្តិការសេដ្ឋកិច្ច" ។ ព្រមគ្នានេះ នៅឆ្នាំ ២០០៣ ពួក"អន្តោប្រវេសន៍" យួន បានសុំឱ្យមានការទទួលស្គាល់ជាផ្លូវការដល់សាខាទាំងអស់នៃ "សមាគមជនជាតិវៀតណាមនៅកម្ពុជា" (ស.វ.ក) ដែលគេបានបង្កើននៅគ្រប់ទីក្រុង និងខេត្តខ្មែរ ទោះជាខេត្តណាមានមនុស្សនៅបន្តិចបន្តួចក្តី ។ ក្រសួងមហាផ្ទៃខ្មែរ បានយល់ព្រមភ្លាម ដោយថែមទាំងទទួលស្គាល់ឱ្យ "ស.វ.ក"នេះ មានត្រាប្រើប្រាស់ផ្ទាល់ខ្លួន តាមត្រូវការផង ។ នេះជាទទួលស្គាល់ជាផ្លូវការនូវរដ្ឋបាលទី២ ទន្ទឹមគ្នានិងរដ្ឋបាល "ខ្មែរ"។

ពួកអាណានិគមយួន បានមកតាំងទីនៅគ្រប់ខេត្ត-ក្រុងខ្មែរទាំងអស់ ខាងក្រុងស្រុក និងជាយដែន។ គេបានប្រមាណថា នៅឆ្នាំ២០០៩ ពួកនេះ មានចំនួនជាង៥លាន់នាក់ ក្នុងចំនួនប្រជាជនទាំងអស់ ១៤លាន់នាក់ ហើយគេមានកម្លាំងគ្រប់សង្កត់ លើនយោបាយ និងសេដ្ឋកិច្ចកម្ពុជា កាន់តែខ្លាំង ឡើងៗជានិច្ច ។

ឌុ.ក

New World Travel II
ញូវឺលត្រាវែលធូ
Specialized in Selling Flight Tickets For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

ខ្មែរប៉ុស្ដិ៍
THE KHMER POST
EAST COAST
The Cambodian-American Biweekly News
Email : Khmerpostusa@gmail.com
Call : 267-254-8758
ផ្សព្វផ្សាយលេខទូរស័ព្ទ និងអាស័យដ្ឋានលោកអ្នក ក្នុងទំព័រកាសែតខ្មែរប៉ុស្ដិ៍ នោះនឹងអាចជួយពាណិជ្ជកម្ម របស់លោកអ្នកឱ្យបង្កើននូវអតិថិជនបានយ៉ាងឆាប់រហ័សឡើង ។

ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
Tel: 215-467-1220
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447
បំរើលោកអ្នកដោយមិត្តភាព និងរាក់ទាក់
- Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ
*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.



មានជំនាញខាងទិញ.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
យើងស្វាគមន៍ចំពោះលោកអ្នកដែលផ្ដើមវិនិយោគ
Vinh Ho, 215-391-9516
Email: vho.realestate@consultant.com
ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148
Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!



# ស្វាគមន៍ឆ្នាំ ២០១០...

តមកពីទំព័រទី ០៩

ទុកជាអនុស្សាវរីយ៍ដល់ភ្ញៀវនាឆ្នាំថ្មី ជាពិសេស អនុស្សាវរីយ៍នៃការជប់លៀងនៅភោជនីយដ្ឋានខ្នាតមធ្យម ដែលមានឈ្មោះខ្មែរ បំរើម្ហូបខ្មែរ ដំបូងគេបង្អស់នៅហ្វីឡាដែលហ្វៀ ។



លោក អ៊ុន តាំងហួ

ជោគជ័យនៃភាពសាមញ្ញនៃរាត្រីចូលឆ្នាំថ្មី ខ្មែរប៉ុស្តិ៍ ក៏ដោយសារជំនួយដ៏ស្មៀមស្ងាត់ តែស្និតស្នាលនៃអ្នកស្រី សូស៊ុមន ចាប់ស្មេរអត្ថបទ "សន្សំតក់ៗ " នៃ សុបិន ថាច់ ជានាយកគ្រប់គ្រងពាណិជ្ជកម្ម, ដាណាលី សែម ស្មេររាយការណ៍ជាភាសាអង់គ្លេស, អ៊ុម លឿម ស្មេរជើងចាស់, អ្នកផ្ដល់ព័តិមានពីស្រុកខ្មែរ ពីឆ្នេរខាងលិច នៃសហរដ្ឋអាមេរិកនោះដែរ ។ អ្នកជំនួយស្មៀមស្ងាត់ផ្សេងទៀត ដែលតែងតែចង់ឃើញខ្មែរប៉ុស្ដិ៍ រីកចំរើន ដូចជា គុជ ឆឹម, រឿម ឡុង, វីសាកា ពេជ, សរិត សម, សរិត ប៉ែន...។ល។ យ៉ាងមិន ប្រណីដៃនឹងពេលវេលា ។ ទោះជាអ្នកមានឈ្មោះ ឬក៏អត់ស្មៀមស្ងាត់ក្ដី យើងមានបំណងរួមតែមួយ បំរើសហគមន៍តាមរយៈខ្មែរប៉ុស្ដិ៍ ហើយសូមឱ្យពរសព្ទសាធុការក្លាយជាការពិតជូនដល់លោកអ្នកអាន ៕



ភ្ញៀវពិសាម្ហូបខ្មែរនៅភោជនីដ្ឋានខ្មែរ "ការី" នាឱកាសដើមឆ្នាំ២០១០

NOEL TAX CONSUL TANTS
LICENSED & INSURED
Financial Services
សេវាប្រកបដោយវិជ្ជាជីវៈ :
- ខ្ចីប្រាក់ទិញផ្ទះ MORTGAGE
- អន្តោប្រវេសន៍ IMMIGRATION
- បកប្រែភាសា TRANSLATION
- ធ្វើប្រថាប់ត្រាបញ្ជាក់លិខិតផ្លូវការ-NOTARY
- មានសេវាមើលកូន នឹងថែទាំផ្ទះសម្បែង
ណូអែល មជ្ឈមណ្ឌលសេវាធ្វើតាក់
សម្រាប់មុខរបរ ឬឯកជន-កត់ត្រាចំណូលចំណាយប្រចាំថ្ងៃនិងប្រចាំត្រីមាស អ្នកឯកទេសចំណាន នឹងធ្វើតាក់យ៉ាងប្រសើរជូនលោកអ្នក
អាស័យដ្ឋាន : 6341RISING SUN AVE
Philadelphia PA 1911
Phone : (215) 821-2443
Fax : (215) 821-2446
E-mail : noel.tax@gmail.com

NEW PHNOM PENH RESTAURANT
○ មីបំពងគ្រឿងសមុទ្រ ○ គុយទាវគោគ-គុយទាវសាច់គោ
○ ផាត់ថៃ ○ ឡុកឡាក់ ○ មាន់ឆាខ្ញី
○ បាយសាច់ជ្រូកអាំង ○ មីកន្ទាំងសាច់គោ ○ បាយឆាសាច់គ្រប់មុខ



TEL.(215) 389-2122
2301 South. 7th Street. Philadelphia, PA 19148
( 7th & Wolf)

Nationwide
Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់គ្នាដោយតម្លៃថោក
Business Liability Insurance ធានារ៉ាប់រងជំនួញលោកអ្នក
Home Insurance ធានារ៉ាប់រងផ្ទះសម្បែង
Health Insurance ធានារ៉ាប់រងសុខភាព
Auto Insurance ធានារ៉ាប់រងរថយន្ត
Life Insurance ធានារ៉ាប់រងជីវិត
Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា
South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036
North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147



ភោជនីយដ្ឋានខ្មែរ
Kavei
CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Phở
320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)
215.952.6688
OPEN 7 DAYS A WEEK
9am-10pm
• ភោជនីយដ្ឋានយើងខ្ញុំ ចាប់ផ្ដើមបើកពីថ្ងៃហើយ!
• មានម្ហូបខ្មែរពិសេសៗជាច្រើនមុខ ម្ហូបថៃ ឡាវ និង ហ្វៀតណាម
• មានទទួលសម្រាប់ពិធីជប់លាង ខួបកំណើត និង ពិធីផ្សេងៗ
• មានតន្ត្រីសម័យកំដររៀងរាល់ល្ងាច ថ្ងៃសុក្រ-សៅរ៍-អាទិត្យ
• លោកអ្នកអាចទូរស័ព្ទមកកក់តុទុកមុនបាន
• មានកន្លែងចតរថយន្ត ដ៏ធំទូលាយ
ត្រីចៀនជូន
ញាំស្វាយខ្ចីបង្គា
អាម៉ុក
សម្លការី នំបុ័ង
20% OFF
DINNER
(min. order $20)
Cannot Combine with Other Offer
Expire: 12/30/09
10% OFF
DINNER TAKE OUT
(min. order $15)
Cannot Combine with Other Offer
Expire: 12/30/09